# ត្រៃសិក្ខា និង ត្រៃលក្ខណ៍

៣❋៣

រៀបរៀងដោយ

## ភិក្ខុ ចិន គេន ឥន្ទប្បញ្ញោ

វត្តពោធិវង្ស ប្រទេសបារាំង

បោះពុម្ពចែកជាធម្មទាន

ដោយ

ពុទ្ធបរិស័ទ វត្តពោធិវង្ស ប្រទេសបារាំង

ព.ស. ២៥៥៧ គ.ស. ២០១៣

អំណោយពីលោក ឡៅ ឃុនសំអាង [illegible] ដើម្បីដាក់ទុកក្នុង eLibrary of Cambodia

កក្កដា 2015

# ត្រៃសិក្ខា និង ត្រៃលក្ខណ៍

រៀបរៀងដោយ

**ភិក្ខុ ចិន គេន ឥន្ទបញ្ញោ**

ពាយកុំព្យូទ័រ និង ចាត់ចែងដោយ

ភិក្ខុ ពេជ្រ សាម៉ុន ចិរវឌ្ឍោ

បោះពុម្ពចែកជាធម្មទាន

លើកទី ២ ចំនួន ៤១១២ ក្បាល

ឧបត្ថម្ភដោយ

ពុទ្ធបរិស័ទ វត្តពោធិវង្ស ប្រទេសបារាំង

ព.ស. ២៥៥៧ គ.ស. ២០១៣

# អារម្ភកថា

៙

ឧបាសិកា លិម ឆេងអ៊ី ចង់បានសៀវភៅធម៌ ត្រៃសិក្ខា និងត្រៃលក្ខណ៍ ចែកជាធម្មទាន ព្រមទាំងបានប្រគេនបច្ច័យចំនួន ១០០០€ សំរាប់ឧបត្ថម្ភការបោះពុម្ពសៀវភៅធម៌នេះផង ។

ខ្ញុំ អាត្មាភាព បានព្យាយាម ស្រាវជ្រាវ រួបរួម សរសេរសៀវភៅធម៌នេះ សរសេរបែបខ្លី ៗ ប៉ុន្តែ អត្ថន័យ មានខ្លឹមសារ ជ្រាលជ្រៅ គួរដល់ការសិក្សាបដិបត្តិ ។ សូមលោក អ្នក យកចិត្តទុក-ដាក់អាន ទើបយល់សេចក្តីខ្លី ៗ នេះបាន ។

គួរឲ្យស្តាយ ឧបាសិកា លិម ឆេងអ៊ី មិនបានឃើញសៀវភៅធម៌នេះទេ ប៉ុន្តែ មុននឹងគាត់ចែកស្ថានទៅ (នៅថ្ងៃអង្គារ ១៤ ឧសភា ២០១៣)គាត់បានយកសំណៅនេះ ទៅអានរួចហើយ។

សូមវិញ្ញាណ នៃ ឧបាសិកា លិម ឆេងអ៊ី អនុមោទនាទទួលយកនូវបុណ្យកុសល ដែលកើតអំពីធម្មទាននេះ ។ ដោយអំណាចនៃធម្មទាននេះ សូមវិញ្ញាណនៃ ឧបាសិកា លិម ឆេងអ៊ី បានទៅសោយសេចក្តីសុខ ក្នុងសុគតិភព កុំបីឃ្លៀងឃ្លាតឡើយ ។

វត្តពោធិវង្ស ប្រទេសបារាំង, ថ្ងៃទី ១៤ ខែឧសភា ឆ្នាំ ២០១៣

ភិក្ខុ ងិន ភេន ឥន្ទប្បញ្ញោ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

៣❋៤

តិស្សោ ឥមា ភិក្ខវេ សិក្ខា ។ កតមា តិស្សោ ។ អធិសីលសិក្ខា អធិចិត្តសិក្ខា អធិបញ្ញាសិក្ខា ។ ម្នាលភិក្ខុ-ទាំងឡាយ សិក្ខានេះមាន ៣ ។ សិក្ខា ៣ តើដូចម្តេច ។ គឺ អធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិបញ្ញាសិក្ខា ១ ។[១]

## សិក្ខា

ការសិក្សា ឲ្យគ្រាន់តែចេះដឹងចំណេះវិជ្ជាផ្សេង ៗ មិនទាន់មានការបដិបត្តិទេ ហៅថា បរិយត្តិ ។ ការសិក្សាផង បដិបត្តិផង ទៅជាមួយគ្នា ឧ. ភិក្ខុ សិក្សាថា អាត្មាអញ ដឹងច្បាស់នូវកាយទាំងពួង ដកដង្ហើមចូល សិក្សាថា អាត្មាអញ ដឹង-ច្បាស់នូវកាយទាំងពួង ដកដង្ហើមចេញ ដូច្នេះជាដើម ហៅថា សិក្ខា ។ គោលធម៌ សំរាប់សិក្សាផង បដិបត្តិផង ទៅជាមួយគ្នា ក៏ហៅថា សិក្ខាដែរ ។

## សិក្ខា ៣

ការសិក្សាផង បដិបត្តិផង ទៅជាមួយគ្នា ដើម្បីអប់រំកាយ

---

[១]-សុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត ៤១-៩១-៣៣៤

វាចា ចិត្ត និង បញ្ញា ឲ្យល្អក្រៃលែងឡើងជាលំដាប់ រហូតអស់កិលេសាសវៈ បានសម្រេចមគ្គផលដល់ព្រះនិព្វាន ហៅថា សិក្ខា ឬ ត្រៃសិក្ខា ។

## សិក្ខា ៣ គឺ :

១-**អធិសីលសិក្ខា** ការសិក្សាបដិបត្តិក្នុងអធិសីល ។

២-**អធិចិត្តសិក្ខា** ការសិក្សាបដិបត្តិក្នុងអធិចិត្ត(សមាធិ) ។

៣-**អធិបញ្ញាសិក្ខា** ការសិក្សាបដិបត្តិ ក្នុងអធិបញ្ញា ។

ឯ ត្រៃសិក្ខា គេច្រើននិយាយកាត់ខ្លីថា **សីល សមាធិ បញ្ញា** ដូច្នេះក៏បាន ។ ចំណែក ព្រះពុទ្ធ ទ្រង់សំដែងថា **អធិសីលសិក្ខា អធិចិត្តសិក្ខា អធិបញ្ញាសិក្ខា** ។

**អធិ** ប្រែថា ក្រៃលែង គឺមិនធម្មតា មិនមែនបដិបត្តិលេង ៗ គម្រប់កិច្ច ឬ បដិបត្តិដើម្បីទៅកើតក្នុងស្ថានសួគ៌ជាដើមនោះទេ គឺ បដិបត្តិយកជីវិតទៅប្តូរ ដើម្បីបានសម្រេចមគ្គផលព្រះនិព្វាន ។

ហេតុនេះ អ្នកបដិបត្តិ អធិសីល មានសិក្ខាបទតិច ឬ សិក្ខាបទច្រើន មិនជាប្រមាណ ប្រការសំខាន់បំផុតគឺ សីល មិនដាច់ មិនធ្លុះ មិនពពុស មិនពពាល ជាសីលអ្នកជា ដែលអ្នកប្រាជ្ញសរសើរ ប្រព្រឹត្តទៅដើម្បីគាំទ្រនូវការចំរើនសមាធិ ។

អ្នកបដិបត្តិ អធិចិត្ត មិនមែនធ្វើសមាធិឲ្យបានឈាន ដើម្បីបានទៅកើតក្នុងព្រហ្មលោកទេ គឺអប់រំចិត្តឲ្យស្ងប់ ដើម្បីបណ្តុះវិបស្សនាបញ្ញា ឲ្យខ្ពស់ឡើង ។ រហូតបានសម្រេចមគ្គផលព្រះនិព្វាន។

អ្នកបដិបត្តិ អធិបញ្ញា ក៏ដូចគ្នា មិនមែនបណ្តុះឲ្យកើតលោកិយបញ្ញាទេ គឺបណ្តុះឲ្យកើតលោកុត្តរបញ្ញា ភ្លឺថ្លាឃើញច្បាស់តាមសេចក្តីពិត នូវសភាវធម៌ អាចកាត់កិលេសាសវៈ ព្រមទាំងឫសគល់ឲ្យអស់រលីង រំលត់នូវកងទុក្ខទាំងមូល សម្រេចព្រះនិព្វាន ។

ខត្តរសង្កេត :

អ្នកបដិបត្តិធម៌ ភាគច្រើន កាន់តែសីលមួយ សមាធិ និងបញ្ញា មិនបដិបត្តិផង ។ កាន់តែសីលមួយ គ្រាន់បើជាងមិនកាន់អ្វីសោះដែរ ប៉ុន្តែ វាមិនគ្រប់គ្រឿងរបស់វាទេ ។ អ្វីដែលរួមផ្សំមិនសព្វគ្រប់តាមរូបមន្តរបស់វា វាមិនអាចចេញលទ្ធផលឲ្យល្អប្រសើរទៅបានទេ ។ **សីល** លំអខាងដើម **សមាធិ** លំអត្រង់កណ្តាល **បញ្ញា** លំអក្នុងទីបំផុត ។ ហេតុនេះ គេត្រូវតែបដិបត្តិ សីល សមាធិ បញ្ញា ទាំង ៣ នេះឲ្យព្រមគ្នា ទើបអាចដល់នូវទីបំផុតទុក្ខ គឺ ព្រះនិព្វាន បាន ។

ម្យ៉ាងទៀត សូមឲ្យគេបដិបត្តិ សីល សមាធិ បញ្ញា ទាំង៣

នេះ ព្រមគ្នាហើយ ក៏ពិតមែន ប៉ុន្តែ សីល សមាធិ បញ្ញា ថ្នាក់ធម្មតា គឺ មិនមែនជាថ្នាក់អធិសីល(អរិយសីល) អធិចិត្ត(អរិយសមាធិ) អធិបញ្ញា(អរិយបញ្ញា) គេក៏នៅតែវិលវល់ក្នុងវដ្តសំសារ មិនអាចឆ្លងទៅរកលោកុត្តរបានឡើយ ។ ហេតុនេះហើយ គេត្រូវតែបដិបត្តិតាម អធិសីល អធិចិត្ត អធិបញ្ញា ទាំង ៣ នេះឲ្យព្រមគ្នា ទើបអាចដល់នូវទីបំផុតទុក្ខ គឺ ព្រះនិព្វាន ។

## ហេតុផលនៃត្រៃសិក្ខា

❀❀❀

ហេតុអ្វី ? សិក្ខា ទើបមានដល់ទៅ ៣ ។ បើមានតិចត្រឹមតែមួយ ឬ ពីរ មិនបានឬ ? បើមានច្រើនដល់ទៅបួន មិនបានទេឬ ? មិនបានទេ មានតិចជាង ៣ មិនបានទេ ព្រោះខ្វះប្រើការមិនគ្រប់ បើមានច្រើនជាង ៣ ក៏មិនបានដែរ ព្រោះវាលើស ឥតប្រយោជន៍ ។ សិក្ខា ជាថ្នាំកំចាត់រោគ គឺ កិលេស ។ កិលេស មាន ៣ យ៉ាង សិក្ខា ក៏ត្រូវមាន ៣ យ៉ាងដែរ ទើបសមគ្នាល្មមមិនខ្វះ មិនលើស ។

## កិលេស ៣ យ៉ាង

១-**វីតិក្កមកិលេស** កិលេសគ្រោតគ្រាត(ធំៗ) **បាណាតិបាត** សម្លាប់សត្វ **អទិន្នាទាន** លួចទ្រព្យគេ **កាមេសុ មិច្ឆាចារ** ប្រព្រឹត្តខុសក្នុងកាម ជាមួយ ប្តី ប្រពន្ធ កូន ចៅ របស់គេជាដើម។

**២-បរិយុដ្ឋានក្កិលេស** កិលេសមធ្យម រួបរុំចិត្ត នៅជិតៗ បម្រុងនឹងចេញជារូបភាពមករឿយ ៗ **កាមច្ឆន្ទ** សេចក្ដីពេញចិត្តនឹងកាមគុណ (ស្រឡាញ់) **ព្យាបាទ** សេចក្ដីគុំកួន (ស្អប់) ជាដើម ។

៣-**អនុសយក្កិលេស** កិលេសល្អិត ដេកសម្ងំនៅក្នុងសន្តានចិត្ត **កាមរាគ** តម្រេកក្នុងកាម **បដិឃ** សេចក្ដីថ្នាំងថ្នាក់ជាដើម ។ អនុសយក្កិលេស ដូចកករនៅក្នុងបាតពាង ឬ បាតស្រះ ពេលធម្មតា ទឹកខាងលើថ្លា អាចប្រើការបាន ប៉ុន្តែ បើមានអ្វីចូលទៅប៉ះពាល់ដល់បាតពាង ឬ បាតស្រះ ពេលនោះកករអណ្ដែតឡើងមក ទឹកប្រែជាល្អក់ ប្រើការលែងបាន ។

បុគ្គលប្រព្រឹត្តកន្លង វិតិក្កមក្កិលេស ផ្សេងៗ ដូចជាកាមេសុ មិច្ឆាចារ ជាដើម ប្រព្រឹត្តកន្លងរួចហើយទៅ វាមិនចប់សូន្យទេ វាមានកាកសំណល់របស់វាជា អនុសយក្កិលេស ល្អិត ៗ ដូចជា កាមរាគ ជាដើម សល់នៅដេកសម្ងំក្នុងសន្តានចិត្តរបស់យើងជាដរាប ។ អនុសយក្កិលេស នោះ ច្រើនឡើង ៗ ប្រៀបដូចភ្នំភ្លើង រង់ចាំតែឱកាសនឹងផ្ទុះតែប៉ុណ្ណោះ ។ **កាមរាគ** នោះ ពេលមានអារម្មណ៍សមគួរដល់វាហើយ វាប្រែខ្លួនជា **កាមច្ឆន្ទ** បន្ទាប់មកជា **កាមេសុ មិច្ឆាចារ** សាជាថ្មីទៀត វិលទៅវិលមកតែយ៉ាងនេះឯង ។ ហេតុនេះ គេត្រូវតែកាត់ផ្ដាច់ អនុសយក្កិលេស

នេះ ឲ្យអស់ឫសអស់គល់ចេញ ទើបអស់បញ្ហា សម្រេច មគ្គ ផល ព្រះនិព្វាន បាន ។

## វិធីកំចាត់កិលេស ៣ យ៉ាង

១-**អធិសីលសិក្ខា** កំចាត់វីតិក្កមក្កិលេស បានសេចក្ដីថា បើគេកាន់អធិសីល ម៉ត់ចត់ត្រឹមត្រូវហើយ អាចកំចាត់កិលេសប្រភេទនេះបាន ។

២-**អធិចិត្តសិក្ខា** គ្របសង្កត់ បរិយុដ្ឋានក្កិលេស បាន សេចក្ដីថា បើគេអប់រំចិត្តជាសមាធិ ត្រឹមត្រូវហើយ អាចគ្របសង្កត់កិលេសប្រភេទនេះ មិនឲ្យកើតឡើងបាន ក្នុងពេលជាសមាធិនោះ ។ ប៉ុន្តែ វាមិនទាន់អស់ឫសគល់ទេ គេត្រូវតែចំរើនធម៌(បញ្ញាឬវិបស្សនា) ឲ្យខ្ពស់ឡើងថែមទៀត ។

៣-**អធិបញ្ញាសិក្ខា** កំចាត់ អនុសយក្កិលេស បានសេចក្ដីថា បើគេអប់រំចិត្តក្នុងអធិបញ្ញាសិក្ខា (វិបស្សនា) ម៉ត់ចត់ត្រឹមត្រូវហើយ អនុសយក្កិលេស នឹងឆេះខ្ទេចខ្ទៀម អស់ឫសអស់គល់ លែងមានបញ្ហាអ្វីតទៅទៀតបានហើយ សម្រេច មគ្គ ផល ព្រះនិព្វាន ចប់ត្រឹមប៉ុណ្ណេះ ។

# មជ្ឈិមា បដិបទា

## ផ្លូវកណ្ដាល

៙

ផ្លូវកណ្ដាល គឺ ផ្លូវនៅចន្លោះ ផ្លូវអមទាំងពីរ គឺ កាមសុខល្លិកានុយោគ ច្របូកច្របល់នឹងកាម ដែលពួកគ្រហស្ថអ្នកស្រុក គេចូលចិត្ត គេបដិបត្តិគ្នា សព្វថ្ងៃ... ។ រីឯ អត្តកិលមថានុយោគ គឺផ្លូវដែលធ្វើ ខ្លួនឲ្យទុក្ខលំបាក ដូចពួកអ្នកបួសខ្លះ គេបដិបត្តិ ស្លៀកពាក់ស្បែកសត្វ ឬ មិនស្លៀកពាក់សោះ បរិភោគស្វៃ ដេកហាលថ្ងៃ ឬ ឆ្អើរភ្លើង ជាដើម ដើម្បីឲ្យស្ងួតកិលេស ។ ផ្លូវកណ្ដាលនេះ ព្រះតថាគត បានត្រាស់ដឹងហើយ ដោយបញ្ញាដ៏ក្រៃលែង ជាផ្លូវធ្វើឲ្យកើតចក្ខុ ឲ្យកើតញាណ ប្រព្រឹត្តទៅដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន ។ បញ្ជាក់បន្ថែមទៀតថា ផ្លូវកណ្ដាល ត្រូវតែប្រកបដោយអង្គ ៨ ហៅថា អដ្ឋង្គិកមគ្គ បើមិនប្រកបដោយ អង្គ ៨ ទេ មិនហៅថា ផ្លូវកណ្ដាល ទេ [២]។

---

[២]-វិនយបិដក មហាខន្ធកៈ ធម្មចក្កប្បវត្តនសូត្រ ៦-១៣-២៨

## អដ្ឋង្គិកមគ្គ

ផ្លូវមួយប្រកបដោយអង្គ ៨ គឺ :

| | | |
|---|---|---|
| ១-**សម្មាទិដ្ឋិ** | ការយល់ឃើញត្រូវ | សង្គ្រោះចូលក្នុង អធិបញ្ញាសិក្ខា (បញ្ញាក្ខន្ធ) |
| ២-**សម្មាសង្កប្បោ** | សេចក្តីត្រិះរិះត្រូវ | |
| ៣-**សម្មាវាចា** | ពាក្យសំដីត្រូវ | សង្គ្រោះចូលក្នុង អធិសីលសិក្ខា (សីលក្ខន្ធ) |
| ៤-**សម្មាកម្មន្តោ** | ការងារត្រូវ | |
| ៥-**សម្មាអាជីវោ** | ការចិញ្ចឹមជីវិតត្រូវ | |
| ៦-**សម្មាវាយាមោ** | សេចក្តីព្យាយាមត្រូវ | សង្គ្រោះចូលក្នុង អធិចិត្តសិក្ខា (សមាធិក្ខន្ធ) |
| ៧-**សម្មាសតិ** | ការរលឹកត្រូវ | |
| ៨-**សម្មាសមាធិ** | ការតាំងចិត្តមាំត្រូវ | |

**សម្មាទិដ្ឋិ** គឺ សេចក្តីដឹងក្នុងទុក្ខ សេចក្តីដឹងក្នុងហេតុ ជាទីកើតឡើងនៃទុក្ខ សេចក្តីដឹងក្នុងការរលត់នៃទុក្ខ សេចក្តីដឹងក្នុងបដិបទាជាដំណើរទៅកាន់ទីរលត់នៃទុក្ខ ។

**សម្មាសង្កប្បោ** គឺ សេចក្តីត្រិះរិះក្នុងការចេញចាកកាម សេចក្តីត្រិះរិះក្នុងការមិនព្យាបាទ សេចក្តីត្រិះរិះក្នុងការមិនបៀតបៀន ។

**សម្មាវាចា** គឺ ចេតនាវៀរចាកការនិយាយកុហក ចេតនាវៀរចាកការនិយាយញុះញង់ ចេតនាវៀរចាកការនិយាយទ្រគោះ ចេតនាវៀរចាកការនិយាយរោយរាយ ។

**សម្មាកម្មន្តោ** គឺ ចេតនាវៀរចាកការសម្លាប់សត្វ ចេតនាវៀរចាកការលួចទ្រព្យគេ ចេតនាវៀរចាកការប្រព្រឹត្តមិនប្រសើរ (សេពមេថុន) ។

**សម្មាអាជីវោ** គឺ សេចក្ដីលះបង់ការចិញ្ចឹមជីវិតខុស ហើយសម្រេចការចិញ្ចឹមជីវិតត្រូវ ។

**សម្មាវាយាមោ** គឺ ព្យាយាមញុំាងពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបាន ព្យាយាមលះបង់នូវពួក អកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ព្យាយាមញុំាងកុសលធម៌ ដែលមិនទាន់កើតឲ្យកើតឡើង ព្យាយាមញុំាងកុសលធម៌ ដែលកើតឡើងហើយ ឲ្យតាំងនៅមិនឲ្យបាត់បង់ទៅវិញ ឲ្យចំរើនធំទូលាយ ពេញបរិបូណ៌ក្រៃលែងឡើង ។

**សម្មាសតិ** គឺ ពិចារណាឃើញរឿយ ៗ នូវកាយក្នុងកាយ ពិចារណាឃើញរឿយ ៗ នូវវេទនាក្នុងវេទនាទាំងឡាយ ពិចារណាឃើញរឿយ ៗ នូវចិត្តក្នុងចិត្ត ពិចារណាឃើញរឿយ ៗ នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស មាន

សេចក្តីដឹងខ្លួន មានស្មារតី កំចាត់បង់នូវអភិជ្ឈា និង ទោមនស្ស ក្នុងលោកចេញ ។

**សម្មាសមាធិ** គឺ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាក អកុសលធម៌ទាំងឡាយ បានដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្ក ប្រកបដោយវិចារ មានតែបីតិ និង សុខ កើតអំពីវិវេក ហើយ សម្រេចសម្រាន្តនៅ ។ បានដល់នូវទុតិយជ្ឈាន ជាធម្មជាតកើត មានក្នុងសន្តានចិត្ត ប្រកបដោយសេចក្តីជ្រះថ្លា គឺ សទ្ធា មានសភាព ជាចិត្តខ្ពស់ឯក មិនមានវិតក្ក មិនមានវិចារ មានតែបីតិ និង សុខ ដែលកើតអំពីសមាធិ គឺ បឋមជ្ឈាន ព្រោះរម្ងាប់វិតក្ក និង វិចារ ហើយសម្រេចសម្រាន្តនៅ ។ មានចិត្តនឿយណាយចាកបីតិ ប្រកបដោយឧបេក្ខា មានស្មារតីដឹងខ្លួន សោយនូវសុខដោយនាមកាយ ព្រះអរិយទាំងឡាយ តែងសរសើរនូវបុគ្គលដែលបាននូវ តតិយជ្ឈាននោះថា បុគ្គលដែលបាននូវតតិយជ្ឈាន មានចិត្តប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះតតិយជ្ឈានណា ក៏បានដល់នូវតតិយជ្ឈាននោះ ហើយ សម្រេចសម្រាន្តនៅ ។ លះបង់នូវសុខផង លះបង់នូវទុក្ខផង មានសោមនស្ស និង ទោមនស្សអស់ហើយក្នុងកាលមុន ក៏បានដល់

នូវចតុត្ថជ្ឈាន ដែលមិនមានទុក្ខ មិនមានសុខ មានតែសតិដ៏បរិ-សុទ្ធ ដែលកើតអំពីឧបេក្ខា ហើយសម្រេចសម្រាន្តនៅ [៣]។

ខគ្លួរសង្កេត :

មជ្ឈិមា បដិបទា ឬ អដ្ឋង្គិកមគ្គ មិនមែនជាអ្វីដទៃទេ គឺជាភាគរួមសំរាប់បដិបត្តិ នៃ ត្រៃសិក្ខា នោះឯង ។ ហេតុនេះ អ្នកបដិបត្តិ គប្បីចំរើនធម៌ ឲ្យទៅជា មគ្គសមង្គី សីល សមាធិ បញ្ញា ទៅជាមួយគ្នា ។

## ឈ្មោះនៃអដ្ឋង្គិកមគ្គ

ព្រះសម្មាសម្ពុទ្ធ សម្ដែងថា ម្នាលអានន្ទ ព្រហ្មយានក្ដី ធម្មយានក្ដី អនុត្តរសង្គាមវិជយយានក្ដី នេះជាឈ្មោះនៃអដ្ឋង្គិកមគ្គ។ រថ គឺ អដ្ឋង្គិកមគ្គ នេះ ប្រកបដោយគ្រឿងប្រដាប់ ដូចតទៅ :

សទ្ធា និង បញ្ញា ជានឹម, សទ្ធា ជាទូក, ហិរិឱត្តប្ប ជាចន្ទោល, មនោ ជាខ្សែបរ, សតិ ជាសារថី, សីល ជាគ្រឿងប្រដាប់តុបតែង, ឈាន ជាភ្លៅ, វីរិយៈ ជាកង់, ឧបេក្ខា ជាកំណល់នឹម, អនិច្ឆា(មិនប្រាថ្នា) ជាដំបូល, អព្យាបាទ អវិហឹសា និងវិវេក ជាអាវុធ, ខន្តិ តីតិក្ខា(អត់ធន់អស្ចារ្យ) ជា

---

[៣]-សុត្តន្តបិដក សំយុត្តនិកាយ មហាវារវគ្គ វិភង្គសូត្រ ៣៧-៣៣-១៨

គ្រឿងគ្រោះ, ប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ជាទីក្សេមចាកយោគៈ។ ព្រហ្មយាន នេះ កើតឡើងក្នុងខ្លួនយើង នៃ បុគ្គលណា បុគ្គលនោះ ជាអ្នកប្រាជ្ញ ចេញចាកលោកនេះ ប្រកបដោយជ័យជំនះ ជយោ ! ជយោ ! ជយោ ! យ៉ាងពិតប្រាកដ [៤]។

ខគ្គរសង្កេត :

គេនិយាយតែ អដ្ឋង្គិកមគ្គ ឯ គ្រឿងប្រដាប់ អដ្ឋង្គិកមគ្គ គេមិននិយាយផង អ្នកខ្លះ មិនទាំងដឹងផង ។ តើយាននេះ អាច ប្រព្រឹត្តទៅបានរលូន ឬ ទេ ? មិនបានទេ ហេតុនេះ អ្នក បដិបត្តិធម៌ ត្រូវបណ្តុះគុណធម៌ទាំងអស់នេះឡើង ទើបការ បដិបត្តិរបស់ខ្លួនយើង មានប្រសិទ្ធិភាពល្អ ។

## ១- វិធីចំរើន អដ្ឋង្គិកមគ្គ

ព្រះសម្មាសម្ពុទ្ធ សម្តែងថា ម្នាលភិក្ខុទាំងឡាយ ការងារ ទាំងឡាយឯណានីមួយ ដែលបុគ្គលត្រូវធ្វើដោយកម្លាំង ការងារ ទាំងអស់នោះ បុគ្គលត្រូវអាស្រ័យនូវផែនដី ឋិតនៅលើផែនដី ទើបធ្វើបាន... យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ អាស្រ័យនូវសីល ឋិតនៅក្នុងសីល ទើបចំរើននូវមគ្គប្រកបដោយ

---

[៤]-សុត្តន្តបិដក សំយុត្តនិកាយ មហាវារវគ្គ ៣៧-២៣-១២

អង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ បាន យ៉ាងនោះដែរ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនា នេះ ចំរើននូវសម្មាទិដ្ឋិ សម្មាសង្កប្បោ ។ល។ សម្មាសមាធិ ដែលអាស្រ័យនូវការស្ងប់ស្ងាត់ (វិវេកនិស្សិតំ) អាស្រ័យនូវការប្រាសចាកតម្រេក (វិរាគនិស្សិតំ) អាស្រ័យនូវការរលត់ (និរោធនិស្សិតំ) បង្អោនទៅរកការលះបង់ (វោស្សគ្គបរិណាមឹ) ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើននូវសម្មាទិដ្ឋិ សម្មាសង្កប្បោ ។ល។ សម្មាសមាធិ មានការកំចាត់បង់នូវរាគៈជាទីបំផុត (រាគវិនយបរិយោសានំ) មានការកំចាត់បង់នូវទោសៈជាទីបំផុត (ទោសវិនយបរិយោសានំ) មានការកំចាត់បង់នូវមោហៈជាទីបំផុត (មោហវិនយបរិយោសានំ) ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើននូវសម្មាទិដ្ឋិ សម្មាសង្កប្បោ ។ល។ សម្មាសមាធិ ដែលចុះស៊ប់កាន់អមតៈ (អមតោគធំ) មានអមតៈប្រព្រឹត្តទៅខាងមុខ (អមតបរាយនំ) មានអមតៈជាទីបំផុត (អមតបរិយោសានំ) ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាស្រ័យនូវសីល ឋិតនៅក្នុងសីល ទើបចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើននូវមគ្គ

ប្រកបដោយអង្គ ៨ ដ៏ប្រសើរបាន យ៉ាងនេះឯង [៤]។

ឧត្តរសង្កេត :

១-អ្នកចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ត្រូវអាស្រ័យនូវសីល ឋិតនៅក្នុងសីល (ជាមុន) មិនមែនចាប់ចំរើនអដ្ឋង្គិកមគ្គហើយ ទើបសីលកើតឡើងក្នុងខណៈនោះទេ ។

២-ចំរើនអដ្ឋង្គិកមគ្គ ត្រូវអាស្រ័យ វិវេក-វិរាគ-និរោធ វោស្សគ្គបរិណាមី បង្អោនទៅដើម្បីលះបង់កិលេស ។ មិនមែនគ្រាន់តែថាដើរតាមអដ្ឋង្គិកមគ្គ ប៉ុន្តែ មិនដែលគិតលះ ឬ បន្ថយកិលេស ម្តងសោះនោះទេ ។

**វិវេក ៥ គឺ :**

1-**វិក្ខម្ភនវិវេក** ស្ងប់ស្ងាត់កិលេសដោយការសង្កត់ទុក គឺ ពេលដែលចិត្តស្ថិតនៅក្នុងឈាន កិលេស នីវរណធម៌ស្ងប់ស្ងាត់មួយរយៈ ។

2-**តទង្គវិវេក** ស្ងប់ស្ងាត់កិលេសដោយអង្គធម៌នោះ គឺ ធម៌ដែល ទំនាស់នឹងគ្នា ស្ងប់ស្ងាត់កំណាញ់ ដោយការឲ្យទានជាដើម។

---

[៤]-សុត្តន្តបិដក សំយុត្តនិកាយ មហាវារវគ្គ ៣៧-២៦៤-១២២

3-**សមុច្ឆេទវិវេក** ស្ងប់ស្ងាត់កិលេសដោយដាច់ខាត គឺលះដោយលោកុត្តរមគ្គ ក្នុងខណៈនៃមគ្គនោះ ។

4-**បដិបស្សទ្ធិវិវេក** ស្ងប់ស្ងាត់កិលេសដាច់ខាត ដោយលោកុត្តរមគ្គនោះហើយ កំពុងស្ថិតនៅក្នុងលោកុត្តរផល ។

5-**និស្សរណវិវេក** ស្ងប់ស្ងាត់កិលេស ដោយរលាស់ចេញអស់រលីង ក្នុងខណៈក្រោយលោកុត្តរផល ចូលដល់អមត-ធាតុ គឺ ព្រះនិព្វាន ។

អ្នកចំរើនអដ្ឋង្គិកមគ្គ អាស្រ័យនូវវិរាគ អាស្រ័យនូវនិរោធ បង្អោនទៅដើម្បីលះបង់ មានអត្ថន័យ ដូចគ្នានឹងវិវេក ជំនួសគ្នាបាន ។

៣-ចំរើនអដ្ឋង្គិកមគ្គ ដើម្បីកំចាត់ រាគៈ ទោសៈ មោហៈ និងដើម្បីមានអមតៈជាទីបំផុត (អមតបរិយោសានំ) ។ មិនមែនចំរើនលេង ។ ឬ គ្រាន់តែឲ្យបានជាឧបនិស្ស័យប៉ុណ្ណោះទេ ។

## ២- ចំរើន អដ្ឋង្គិកមគ្គ

រមែងធ្វើ សតិប្បដ្ឋានឲ្យពេញបរិបូណ៌

ព្រះសម្មាសម្ពុទ្ធ សម្តែងថា ម្នាលភិក្ខុទាំងឡាយ ខ្យល់ផ្សេងៗ រមែងបក់ទៅក្នុងអាកាស គឺខ្យល់ទិសខាងកើតខ្លះ ខ្យល់ទិសខាងលិចខ្លះ ខ្យល់ទិសខាងជើងខ្លះ ខ្យល់ទិសខាងត្បូងខ្លះ ខ្យល់មាន

ធូលីខ្លះ ខ្យល់មិនមានធូលីខ្លះ ខ្យល់ត្រជាក់ខ្លះ ខ្យល់ក្តៅខ្លះ ខ្យល់ខ្សោយខ្លះ ខ្យល់ខ្លាំងខ្លះ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ កាលចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ កាលធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ រមែងធ្វើ សតិប្បដ្ឋាន ៤ក្តី សម្មប្បធាន ៤ ក្តី ឥទ្ធិបាទ ៤ ក្តី ឥន្ទ្រិយ ៥ ក្តី ពលៈ ៥ ក្តី ពោជ្ឈង្គ ៧ ក្តី ឲ្យពេញបរិបូណ៌បាន ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ កាលចំរើន... កាលធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដូម្តេច រមែងធ្វើសតិប្បដ្ឋាន ៤ ក្តី... ឲ្យពេញបរិបូណ៌បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ កាលចំរើន... កាលធ្វើឲ្យច្រើន នូវមគ្គ ប្រកបដោយអង្គ ៨ ដ៏ប្រសើរ អាស្រ័យនូវការស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោនទៅរកការ លះបង់ យ៉ាងនេះឯង រមែងធ្វើ សតិប្បដ្ឋាន ៤ក្តី... ឲ្យពេញបរិបូណ៌បាន [១]។

ខគ្គរសង្កេត :

ចំរើនតែអដ្ឋង្គិកមគ្គ ដ៏ប្រសើរមួយ ឲ្យត្រឹមត្រូវម៉ត់ចត់ ពោធិបក្ខិយធម៌ឯទៀតមាន សតិប្បដ្ឋាន ៤ ជាដើម រមែងដល់នូវ

---

[១]-សុត្តន្តបិដក សំយុត្តនិកាយ មហាវគ្គ ៣៧-២៨៣-១៣៥

ការពេញបរិបូណ៌បានសព្វគ្រប់ដោយប្រការទាំងពួង ។

## ៣- ចំរើន អដ្ឋង្គិកមគ្គ

រមែងកំណត់ដឹងនូវធម៌ដែលគួរកំណត់ដឹងដោយបញ្ញាដ៏ក្រៃលែង

❋❋❋

ព្រះសម្មាសម្ពុទ្ធ សម្តែងថា ពួកមនុស្សមកកាន់ផ្ទះសំរាប់ទទួលភ្ញៀវអំពីទិសខាងកើត សម្រេចការនៅក្នុងផ្ទះនោះក្តី មកអំពីទិសខាងលិច... មកអំពីទិសខាងជើង... មកអំពីទិសខាងត្បូង សម្រេចការស្នាក់នៅក្តី ទោះជាក្សត្រិយក្តី ជាព្រាហ្មណ៍ក្តី ជាវេស្សៈក្តី ជាសុទ្រៈក្តី យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ កាលចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ កាលធ្វើឲ្យច្រើន នូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ រមែងកំណត់ដឹងនូវធម៌ដែលគួរកំណត់ដឹងដោយបញ្ញាដ៏ក្រៃលែង រមែងលះបង់នូវធម៌ដែលគួរលះបង់ដោយបញ្ញាដ៏ក្រៃលែង រមែងធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ក្រៃលែង រមែងចំរើននូវធម៌ដែលគួរចំរើនដោយបញ្ញាដ៏ក្រៃលែង យ៉ាងនោះដែរ ។

ម្នាលភិក្ខុទាំងឡាយ ចុះធម៌ដែលគួរកំណត់ដឹង ដោយបញ្ញាដ៏ក្រៃលែង តើដូចម្តេច ។ គឺ ឧបាទានក្ខន្ធ ៥ ។ ឧបាទានក្ខន្ធ ៥ គឺ :

១-រូបូបាទានក្ខន្ធ ២-វេទនូបាទានក្ខន្ធ ៣-សញ្ញូបាទានក្ខន្ធ

៤-សង្ខារូបាទានក្ខន្ធ ៥-វិញ្ញាណូបាទានក្ខន្ធ ។ ចុះធម៌ដែលគួរលះបង់ដោយបញ្ញាដ៏ក្រៃលែង តើដូចម្ដេច ។ គឺ អវិជ្ជា ១ ភវតណ្ហា ១ ។ ចុះធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ក្រៃលែង តើដូចម្ដេច ។ គឺ វិជ្ជា ១ វិមុត្តិ ១ ។ ចុះធម៌ដែលគួរចំរើនដោយបញ្ញាដ៏ក្រៃលែង តើដូចម្ដេច ។ គឺ សមថៈ ១ វិបស្សនា ១ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុ កាលចំរើន... កាលធ្វើឲ្យច្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ អាស្រ័យនូវការស្ងប់ស្ងាត់ អាស្រ័យនូវការប្រាសចាកតម្រេក អាស្រ័យនូវការរលត់ បង្អោនទៅរកការលះបង់ រមែងកំណត់ដឹងនូវធម៌ដែលគួរកំណត់ដឹងដោយបញ្ញាដ៏ក្រៃលែង រមែងលះបង់នូវធម៌ដែលគួរលះបង់ដោយបញ្ញាដ៏ក្រៃលែង រមែងធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ក្រៃលែង រមែងចំរើននូវធម៌ដែលគួរចំរើន ដោយបញ្ញាដ៏ក្រៃលែង យ៉ាងនេះឯង [៧]។

ខគួរសង្កេត ៖

ចំរើនតែ អដ្ឋង្គិកមគ្គ ដ៏ប្រសើរមួយ ឲ្យត្រឹមត្រូវម៉ត់ចត់

---

[៧]-សុត្តន្តបិដក សំយុត្តនិកាយ មហាវារវគ្គ ៣៧-២៩០-១៣៩

កិច្ចនៃអរិយសច្ច គឺៈ បរិញ្ញេយ្យកិច្ច បហាតព្វកិច្ច សច្ឆិកាតព្វកិច្ច ភាវេតព្វកិច្ច ក៏ឈ្មោះថា បានបំពេញសព្វគ្រប់ទាំងអស់ហើយ ។

## សតិប្បដ្ឋាន

❁❁❁

ព្រះសម្មាសម្ពុទ្ធ សម្ដែងថា ៈ

**ឯកាយនោ អយំ ភិក្ខវេ មគ្គោ សត្តានំ វិសុទ្ធិយា...** ម្នាលភិក្ខុទាំងឡាយ ផ្លូវនេះ ជាផ្លូវមូលតែមួយ ដើម្បីសេចក្ដីបរិសុទ្ធិនៃសត្វទាំងឡាយ ដើម្បីកន្លងបង់នូវសេចក្ដីសោក និង សេចក្ដីខ្សឹកខ្សួល ដើម្បីរំលត់នូវទុក្ខ និង ទោមនស្ស ដើម្បីបន្ទុះនូវធម៌ ដ៏ក្រៃលែង(អដ្ឋង្គិកមគ្គ) ដើម្បីធ្វើឲ្យជាក់ច្បាស់ (សម្រេច) នូវព្រះនិព្វាន ផ្លូវនោះគឺ សតិប្បដ្ឋាន ៤ ប្រការ ៈ

១-**កាយេ កាយានុបស្សី វិហរតិ** ភិក្ខុ(អ្នកបដិបត្តិធម៌) ពិចារណាឃើញរឿយ ៗ នូវកាយក្នុងកាយ **អាតាបី សម្បជានោ សតិមា** មានសេចក្ដីព្យាយាមជាគ្រឿងដុតកម្ដៅកិលេស មានសេចក្ដីដឹងខ្លួន មានស្មារតី **វិនេយ្យ លោកេ អភិជ្ឈា-ទោមនស្សំ** កំចាត់បង់នូវអភិជ្ឈា និង ទោមនស្ស ក្នុងលោកចេញ ។

២-**វេទនាសុ វេទនានុបស្សី វិហរតិ...** ពិចារណាឃើញរឿយ ៗ នូវវេទនាក្នុងវេទនាទាំងឡាយ មានសេចក្ដីព្យាយាម

ជាគ្រឿងដុតកម្តៅកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កំចាត់បង់នូវអភិជ្ឈា និង ទោមនស្ស ក្នុងលោកចេញ ។

៣-**ចិត្តេ ចិត្តានុបស្សី វិហរតិ...** ពិចារណាឃើញរឿយ ៗ នូវចិត្តក្នុងចិត្ត មានសេចក្តីព្យាយាម... ។ល។ កំចាត់បង់នូវអភិជ្ឈា និង ទោមនស្ស ក្នុងលោកចេញ ។

៤-**ធម្មេសុ ធម្មានុបស្សី វិហរតិ...** ពិចារណាឃើញរឿយ ៗ នូវធម៌ក្នុងធម៌ទាំងឡាយ មានសេចក្តីព្យាយាម... ។ល។ កំចាត់បង់នូវអភិជ្ឈា និង ទោមនស្ស ក្នុងលោកចេញ [៨]។

ខត្តរសង្កេត :

ព្រះសូត្រនេះ ឈ្មោះមហាសតិប្បដ្ឋានសូត្រ ។ មុនដំបូងបង្អស់ ព្រះពុទ្ធ សម្តែងប្រាប់ផ្លូវមូលតែមួយ គឺរួម សីល សមាធិ បញ្ញា ទៅជាមួយគ្នា និង ប្រាប់ទិសដៅដែលត្រូវទៅដល់គឺ សេចក្តីបរិសុទ្ធ ផុតទុក្ខ សោក និង ការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ផ្លូវនោះគឺ សតិប្បដ្ឋាន ។ សតិប្បដ្ឋាន ប្រែថា អារម្មណ៍ សំរាប់តាំងឬតម្កល់ សតិ ។ តម្កល់ សតិ គឺ តម្កល់ ចិត្ត ព្រោះសតិ កើតជាមួយចិត្ត ។ តម្កល់ចិត្ត ធ្វើអ្វី ? តម្កល់ចិត្តឲ្យវានឹង កុំឲ្យវារត់

---

[៨]-សុត្តន្តបិដក ទីឃនិកាយ មហាវគ្គ ១៧-១១១-២៤៤

ឆ្វេឆ្វា ទៅរកអារម្មណ៍ផ្សេងៗនាំឲ្យកើតបាប... តម្កល់ចិត្តឲ្យវានឹង ដើម្បីនឹងបណ្ដុះបញ្ញា វិបស្សនា ឲ្យដឹងច្បាស់នូវសភាវធម៌ តាមសេចក្ដីពិត ។ សតិប្បដ្ឋាន អារម្មណ៍សំរាប់តម្កល់សតិ មាន ៤ គឺ ១-កាយ ២-វេទនា ៣-ចិត្ត ៤-ធម៌ ។ មានត្រឹម ៤ ប៉ុណ្ណឹង គ្រប់គ្រាន់ល្មម មិនខ្វះ មិនលើស ។ ពាក្យថា កាយ ជារូបធម៌ គឺជារបស់ទទួលអារម្មណ៍មិនបាន ដឹងអារម្មណ៍មិនបាន ។ ពាក្យថា វេទនា ចិត្ត ជានាមធម៌ មិនមានរូបទេ ប៉ុន្តែ វាទទួលអារម្មណ៍បាន ដឹងអារម្មណ៍បាន ដឹងសុខ ដឹងទុក្ខ ដឹងល្អ ដឹងអាក្រក់ ជាដើម ។ ពាក្យថា ធម៌ ជារបស់ទូទៅ ជារូបធម៌ក៏បាន ជានាមធម៌ក៏បាន គឺមានទាំងពីរបែបនេះ ។

បន្ទាប់មក ព្រះអង្គ ទ្រង់សម្ដែងប្រាប់ វិធីបដិបត្តិធម៌ ភិក្ខុ (ឬអ្នកបដិបត្តិធម៌) គប្បីឧស្សាហ៍ពិចារណាឲ្យឃើញរឿយ ៗ នូវកាយក្នុងកាយ គឺឲ្យស្គាល់កាយឲ្យច្បាស់ កាយហ្នឹងវាជាអ្វី ? ជាមនុស្ស ឬ សត្វ... ? គប្បីពិចារណាឲ្យឃើញរឿយ ៗ នូវវេទនាក្នុងវេទនាទាំងឡាយ នូវចិត្តក្នុងចិត្ត នូវធម៌ក្នុងធម៌ទាំងឡាយ ។ វេទនា ចិត្ត ធម៌ ហ្នឹង វាជាអ្វី ជាមនុស្ស ជាសត្វ ឬ ជាអ្វី ? ស្គាល់ឲ្យច្បាស់ ឃើញឲ្យច្បាស់ ។ **អាតាបី** ព្យាយាមដុតកម្ដៅកិលេស **សម្បជានោ** មានសម្បជញ្ញៈ **សតិមា** មានសតិ បានសេចក្ដីថា គប្បីមានសតិ សម្បជញ្ញៈ ព្យាយាមប្រឹងប្រែងឲ្យមែន

ទែន មិនមែនធ្វើលេង ។ ធ្វើដែរ... ទេ ។ មានសតិ សម្បជញ្ញៈ ព្យាយាមប្រឹងប្រែង តើព្យាយាមប្រឹងប្រែងធ្វើអ្វី ? ដើម្បីអ្វី ? ឆ្លើយថា មានសតិ សម្បជញ្ញៈ ព្យាយាមប្រឹងប្រែងពិចារណាឲ្យ-ឃើញច្បាស់នូវ កាយ វេទនា ចិត្ត ធម៌ ហើយដើម្បីកំចាត់បង់នូវ អភិជ្ឈា សេចក្ដីពេញចិត្ត ទោមនស្ស សេចក្ដីមិនពេញចិត្តក្នុងលោក គឺក្នុងធម៌ដែលកំពុងពិចារណាហ្នឹង គឺ កាយ វេទនា ចិត្ត ធម៌ ឯណានីមួយ កុំស្រឡាញ់ កុំស្អប់វា វាគ្រាន់តែជាកាយ វេទនា ចិត្ត ធម៌ ប៉ុណ្ណោះ [៩]។

## កាយានុបស្សនាសតិប្បដ្ឋាន

❁❁❁

បន្តទៅទៀត ព្រះសម្មាសម្ពុទ្ធ ទ្រង់សំដែងឲ្យពិស្ដារនូវសតិប្បដ្ឋាន ៤ ដូចតទៅ -

១-កាយ ក្នុងសតិប្បដ្ឋាន ចែកចេញជា ៦ យ៉ាង (បព្វ) គឺ ១-អានាបានបព្វៈ ខ្យល់ដង្ហើមចូល-ចេញ ២-ឥរិយាបថបព្វៈ ដើរ ឈរ អង្គុយ ដេក ៣-សម្បជញ្ញបព្វៈ ឈានទៅមុខ ថយក្រោយ ងាកស្ដាំ ឆ្វេង ស្លៀកស្បង់ ពាក់ចីវរ ឆាន់ចង្ហាន់ បត់ជើងតូច ធំ

---

[៩]-មតិខ្វះថា ក្នុងលោក គឺ ចិត្ត ឬ បញ្ចក្ខន្ធ ប៉ុន្តែ មតិនេះ វាមិនត្រូវតាមសាច់រឿង ដែលកំពុងពិចារណាឃើញនោះទេ ។

និយាយស្តី ឬ នៅស្ងៀម មានស្មារតី ដឹងខ្លួនជានិច្ច ៤-បដិក្កូល បព្វៈ សក់ រោម ក្រចក ធ្មេញ ស្បែក ។ល។ ជារបស់បដិក្កូល គួរខ្ពើមរអើម ៥-ធាតុបព្វៈ រូបកាយយើង ជាធាតុ ៤ គឺ ដី ទឹក ភ្លើង ខ្យល់ ៦-នវសីវថិកាបព្វៈ មនុស្សយើង ទីបំផុត ត្រូវស្លាប់ ទៅជាសាកសព សរីររាងកាយ ហើមប៉ោង ជាចំណីនៃពួកសត្វ ឯគ្រោងឆ្អឹង យូរទៅ ពុកផុយ ហុយតាមខ្យល់ ឬ ហូរតាមទឹក អស់រលីង ។ របស់ទាំង ៦ យ៉ាងនេះ ជារូបកាយរបស់យើង ជារបស់ជាប់ទាក់ទងនឹងរូបកាយរបស់យើង ប៉ុន្តែ ដល់ទីបំផុតទៅ វាស្លាប់ វារលត់ សូន្យសោះ អស់រលីងទៅ យ៉ាងនេះឯង ។

នៅខាងចុង បទធម៌នីមួយ ៗ (កាយ វេទនា ចិត្ត ធម៌) ព្រះអង្គ សំដែងសង្កត់ធ្ងន់ វិធីបដិបត្តិ ដូចនេះ -

-**អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ** ភិក្ខុ (អ្នកបដិបត្តិធម៌) ពិចារណាឃើញរឿយ ៗ នូវកាយ ក្នុងកាយ ខាងក្នុងផង ។

-**ពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ** ពិចារណាឃើញរឿយ ៗ នូវកាយ ក្នុងកាយ ខាងក្រៅផង ។

-**អជ្ឈត្តពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ** ពិចារណាឃើញរឿយ ៗ នូវកាយ ក្នុងកាយ ទាំងខាងក្នុង ទាំងខាងក្រៅផង ។

-**សមុទយធម្មានុបស្សី វា កាយស្មឹ វិហរតិ** ពិចារណាឃើញរឿយ ៗ នូវធម៌ គឺ ការប្រជុំកើតឡើង ក្នុងកាយផង ។

-**វយធម្មានុបស្សី វា កាយស្មឹ វិហរតិ** ពិចារណាឃើញរឿយ ៗ នូវធម៌ គឺ ការរលត់ទៅ ក្នុងកាយផង ។

-**សមុទយវយធម្មានុបស្សី វា កាយស្មឹ វិហរតិ** ពិចារណាឃើញរឿយ ៗ នូវធម៌ គឺ ការប្រជុំកើតឡើង និង ការរលត់ទៅ ក្នុងកាយផង ។

-**អត្ថិ កាយោតិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ យាវទេវ ញាណមត្តាយ បតិស្សតិមត្តាយ** ម្យ៉ាង សតិរបស់ភិក្ខុនោះ តាំងមាំថា កាយមានមែន គ្រាន់តែដើម្បីជាទីដឹង (របស់ញាណ) គ្រាន់តែដើម្បីជាទីរលឹក (របស់សតិ) មិនមាន ជាសត្វ បុគ្គល ឬ យើង គេ ទេ ។

-**អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ** ម្យ៉ាង ភិក្ខុនោះ មិនមានចិត្តអាស្រ័យ (គឺ មិនមាន តណ្ហា និង ទិដ្ឋិ) និង មិនមាន ឧបាទាន សេចក្ដីប្រកាន់មាំ អ្វី ៗ ក្នុងលោកឡើយ ។

ភិក្ខុ ពិចារណាឃើញរឿយ ៗ នូវកាយ ក្នុងកាយ យ៉ាងនេះឯង ។

ខគួរសង្កេត :

ពាក្យតទៅនេះ តើមានអត្ថន័យ ដូចម្តេច ?

នូវកាយ ក្នុងកាយ ខាងក្នុង

នូវកាយ ក្នុងកាយ ខាងក្រៅ

។ល។

នូវធម៌ គឺការប្រជុំកើតឡើង ក្នុងកាយ

នូវធម៌ គឺការរលត់ទៅ ក្នុងកាយ

។ល។

ពាក្យថា នូវកាយ សំដៅយកកាយ (អារម្មណ៍) ដែលកំពុងពិចារណា,

ពាក្យថា ក្នុងកាយ សំដៅយកក្នុងបណ្តាកាយទាំងឡាយជាច្រើន,

ពាក្យថា ខាងក្នុង គឺរបស់ខ្លួន ពាក្យថា ខាងក្រៅ គឺរបស់អ្នកដទៃ ។

ពាក្យថា ការប្រជុំកើតឡើង សំដៅយកការកើតឡើង ជាខ្យល់ ដង្ហើមចូល ចេញក្តី កើតឡើងជាឥរិយាបថ ដើរ ឈរ អង្គុយ ដេក ក្តី ។ល។ កើតជា វេទនា ចិត្ត ធម៌ ក្តី តើកើតឡើងដោយ អាស្រ័យអ្វី...,

ពាក្យថា ការរលត់ទៅ តើរលត់ទៅដោយហេតុអ្វី ?

តាមផ្លូវធម៌ ការប្រជុំកើតឡើង សុទ្ធតែមានហេតុ មិនមានអ្វីកើតឡើង ប្រាសចាកហេតុទេ បើហេតុប្រែប្រួល របស់ដែលកើតឡើងនោះ ប្រែប្រួល បើហេតុរលត់ទៅ របស់ដែលកើតឡើងនោះ ត្រូវតែរលត់ទៅវិញដែរ ។

ហេតុនេះ មិនមានអ្វី ជាយើង ជាគេ ឬ ជារបស់យើង ជារបស់គេ ទេ ។ យើង គេ របស់យើង របស់គេ គ្រាន់តែជាការសន្មត ឬ បញ្ញត្តិ ប៉ុណ្ណោះ ។

អ្នកបដិបត្តិធម៌ គប្បីសិក្សាបដិបត្តិ តាមព្រះឱវាទសង្កត់ធ្ងន់ខាងចុង អត្ថបទធម៌នីមួយ ៗ ឲ្យបានត្រឹមត្រូវម៉ត់ចត់ចុះ ។

## វេទនានុបស្សនា សតិប្បដ្ឋាន

❁❁❁

វេទនា ក្នុងសតិប្បដ្ឋាន មាន ៣ គឺ : ១-**សុខវេទនា** ២-**ទុក្ខវេទនា** ៣-**អទុក្ខមសុខវេទនា** (ឧបេក្ខាវេទនា) ។ ក្នុងវេទនាមួយ ៗ ចែកចេញជា ២ គឺ ១-**សាមិស** ប្រកបដោយអាមិស គឺបញ្ចកាមគុណ មាន រូប សម្លេង ជាដើម ២-**និរាមិស** មិនប្រកបដោយអាមិស តែប្រកបដោយនេក្ខម្មៈ មានការបដិបត្តិធម៌ជាដើម បានទៅជា ៦ ថែមទៀត បូករួមនឹងវេទនាដើម(៣+៦=៩) ត្រូវជាវេទនា មាន ៩ យ៉ាង ។

ភិក្ខុ ក្នុងសាសនានេះ កាលទទួលសុខវេទនា ប្រកបដោយ

អាមិសក្តី ក៏ដឹងច្បាស់ថា អាត្មាអញ ទទួលសុខវេទនា ប្រកបដោយអាមិស, កាលទទួលសុខវេទនា មិនប្រកបដោយអាមិសក្តី ក៏ដឹងច្បាស់ថា អាត្មាអញ ទទួលសុខវេទនា មិនប្រកបដោយអាមិស... ។ល។

ភិក្ខុ ពិចារណាឃើញ រឿយៗនូវវេទនា ក្នុងវេទនាទាំងឡាយខាងក្នុង... ខាងក្រៅ... ទាំងខាងក្នុងទាំងខាងក្រៅ... ។ល។

សតិ របស់ភិក្ខុនោះ តាំងមាំថា វេទនា មានមែន គ្រាន់តែដើម្បីជាទីដឹង គ្រាន់តែដើម្បីជាទីរលឹក មិនមានជា សត្វ បុគ្គល យើង គេ ទេ ។

ភិក្ខុនោះ មិនមាន តណ្ហា ទិដ្ឋិ (មានះ) និង ឧបាទាន សេចក្តីប្រកាន់មាំនូវអ្វីៗ ក្នុងលោកឡើយ ។

ភិក្ខុ ពិចារណាឃើញរឿយ ៗ នូវវេទនា ក្នុងវេទនា ទាំងឡាយ យ៉ាងនេះឯង ។

ខគ្គរសង្កេត

ភិក្ខុ កាលទទួលសុខវេទនា ប្រកបដោយអាមិសក្តី ក៏ដឹងច្បាស់ថា អាត្មាអញ ទទួលសុខវេទនា ប្រកបដោយអាមិស...។ គិតសើៗ ដូចជាធម្មតា មិនឃើញជាការបដិបត្តិធម៌ អ្វី ប៉ុន្តែ បើគិតឲ្យជ្រៅ ទើបយល់អត្ថន័យនេះបាន ។ វេទនា កើតរលត់ៗ

ឥតឈប់ឈរ បើមិនសុខវេទនា ក៏ទុក្ខវេទនា ឬក៏ អទុក្ខមសុខវេទនា ប៉ុន្តែ គេមិនមាន សតិ ដឹងរហូតទេ ទាល់តែមានសុខវេទនា ឬ ទុក្ខវេទនា យ៉ាងខ្លាំង ។ ទើបគេដឹងថា សុខវេទនា ឬទុក្ខវេទនា បើគ្រាន់តែមាន វេទនាមិនទុក្ខមិនសុខល្មម ។ គេមិនមានសតិ ដឹងទេ គេព្រងើយ ។ អត់គិតអ្វីទាំងអស់ ។ នេះ ចាត់ទុកជាកំហុសហើយ អវិជ្ជា កើតឡើងហើយ បាបកើតឡើងហើយ។ ព្រោះហេតុដូច្នោះ ទើបព្រះពុទ្ធ ទ្រង់យស ណែនាំឲ្យមានសតិដឹងទាន់គ្រប់ពេលវេលា ទាំងអស់ ។

ម្យ៉ាងទៀត មនុស្សយើង ច្រើនយល់ ច្រើនតែសំគាល់យកមែនទែនថា មានអញ មានឯង មានតួខ្លួន ជាអ្នកទទួលសុខទុក្ខ ។ ប៉ុន្តែ តាមសេចក្តីពិត ការទទួលសុខ ទុក្ខ ...នោះ គ្រាន់តែជាក្រសែធម៌ប៉ុណ្ណោះទេ ។ បានសេចក្តីថា កាលណាមានការប៉ះទង្គិចរវាងអាយតនៈខាងក្នុង មានភ្នែកជាដើម ជាមួយនឹងអាយតនៈខាងក្រៅ មានរូបជាដើម វិញ្ញាណ មានចក្ខុវិញ្ញាណជាដើមកើតឡើង ។ ប្រជុំធម៌ ៣ យ៉ាងនេះ ហៅថា ផស្សៈ ផស្សបច្ចយា វេទនា ព្រោះមានផស្សៈជាបច្ច័យ ទើបវេទនា កើតឡើងបាន ។ វេទនានោះហើយ ជាអ្នកទទួល សុខ ទុក្ខ... ជាដើម មិនមាន សត្វ បុគ្គល យើង គេ ជាអ្នកទទួល សុខ ទុក្ខ.. ទេ ។ ព្រោះហេតុនោះហើយ ទើបព្រះសម្មាសម្ពុទ្ធ សម្តែងថា វេទនា

មានមែន គ្រាន់តែដើម្បីជាទីដឹង គ្រាន់តែដើម្បីជាទីរលឹក មិនមានជា សត្វ បុគ្គល យើង គេ ទេ កុំស្រឡាញ់ កុំស្អប់ កុំប្រកាន់មាំនូវអ្វី ៗ ក្នុងលោកឡើយ ។

សូមជម្រាបបន្ថែមថា អ្នកមានជម្ងឺ កំពុងទទួលទុក្ខវេទនាក្ដី អ្នកបដិបត្តិធម៌ កំពុងឈឺចុកចាប់ ព្រោះអង្គុយបដិបត្តិក្ដី គប្បីយករឿង (វេទនា) នោះ ជាអារម្មណ៍ ហើយចំរើន វេទនានុបស្សនាសតិប្បដ្ឋាន ក៏ទុកជាការត្រឹមត្រូវដូចគ្នា ។

## ចិត្តានុបស្សនា សតិប្បដ្ឋាន

❋❋❋

**ចិត្ត** ក្នុងសតិប្បដ្ឋាន មាន ១៦ យ៉ាង គឺ :

១-**សរាគ** ចិត្តប្រកបដោយរាគៈ

២-**វីតរាគ** ចិត្តប្រាសចាករាគៈ

៣-**សទោស** ចិត្តប្រកបដោយទោសៈ

៤-**វីតទោស** ចិត្តប្រាសចាកទោសៈ

៥-**សមោហ** ចិត្តប្រកបដោយមោហៈ

៦-**វីតមោហ** ចិត្តប្រាសចាកមោហៈ

៧-**សង្ខិត្ត** ចិត្តរួញរា (ថីនមិទ្ធៈ)

៨-**វិក្ខិត្ត** ចិត្តរាយមាយ (ឧទ្ធច្ចៈ)

៩-**មហគ្គត** ចិត្តដល់នូវភាវៈប្រសើរ (រូបាវចរចិត្ត និង អរូបាវចរចិត្ត)

១០-**អមហគ្គត** ចិត្តមិនដល់នូវភាវៈប្រសើរ (កាមាវចរចិត្ត)

១១-**សឧត្តរ** ចិត្តនៅមានចិត្តដទៃប្រសើរជាង (កាមាវចរ-ចិត្ត)

១២-**អនុត្តរ** ចិត្តមិនមានចិត្តដទៃប្រសើរជាង (រូបាវចរចិត្ត និងអរូបាវចរចិត្ត)

១៣-**សមាហិត** ចិត្តជាសមាធិ (ឧបចារសមាធិ និង អប្បនាសមាធិ)

១៤-**អសមាហិត** ចិត្តមិនសមាធិ (ប្រាសចាកសមាធិទាំងពីរនោះ)

១៥-**វិមុត្ត** ចិត្តរួចផុត (វិក្ខម្ភនវិមុត្តិ និង តទង្គវិមុត្តិ)

១៦-**អវិមុត្ត** ចិត្តមិនរួចផុត (ប្រាសចាកវិមុត្តិទាំងពីរនោះ)

ភិក្ខុ ក្នុងសាសនានេះ ទោះចិត្តប្រកបដោយរាគៈ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ, ចិត្តប្រាសចាករាគៈ ក៏ដឹងច្បាស់ថា ចិត្តប្រាសចាករាគៈ ។ល។ ចិត្តរួចផុត ក៏ដឹងច្បាស់ថា ចិត្តរួចផុត, ចិត្តមិនរួចផុត ក៏ដឹងច្បាស់ថា ចិត្តមិនរួចផុត ។

ភិក្ខុ ពិចារណាឃើញរឿយ ៗ នូវចិត្ត ក្នុងចិត្ត ខាងក្នុង... ខាងក្រៅ... ទាំងខាងក្នុងទាំងខាងក្រៅ ។ ភិក្ខុ ពិចារណាឃើញរឿយ ៗ

នូវការប្រជុំកើតឡើង និង ការរលត់ក្នុងចិត្ត... ។ល។

សតិ របស់ភិក្ខុនោះ តាំងមាំថា ចិត្ត មានមែន គ្រាន់តែដើម្បីជាទីដឹង ដើម្បីជាទីរលឹក មិនមានជា សត្វ បុគ្គល យើង គេ ទេ ។

ភិក្ខុនោះ មិនមាន តណ្ហា ទិដ្ឋិ (មានះ) និង ឧបាទាន សេចក្ដីប្រកាន់មាំនូវអ្វី ៗ ក្នុងលោកឡើយ ។

ភិក្ខុ ពិចារណាឃើញរឿយ ៗ នូវចិត្ត ក្នុងចិត្ត យ៉ាងនេះឯង ។

ខត្តរសង្កេត :

ភិក្ខុ (អ្នកបដិបត្តិធម៌) មិនយកអ្វីដទៃ អាចយកចិត្តរបស់ខ្លួនជាអារម្មណ៍របស់ចិត្ត ចំរើនធម៌បាន ។ បានសេចក្ដីថា ភិក្ខុ យកចិត្តសង្កេតមើលចិត្ត ពិចារណាចិត្ត តើចិត្តយ៉ាងណា ? កំពុងត្រូវកិលេសអ្វី គ្របសង្កត់ ឬ កំពុងស្ថិតនៅក្នុងភូមិណា ? ចិត្ត រួចផុត ឬក៏ ជាប់ជំពាក់ ។ ព្រោះតាមធម្មតា មនុស្សយើង មិនសូវមើលខ្លួនឯងទេ មិនសូវស្គាល់ខ្លួនឯងច្បាស់ទេ ច្រើនតែមើលអ្នកដទៃ ឃើញទោស ឃើញកំហុសអ្នកដទៃ ឯត្រង់ខ្លួនឯង មើលឃើញច្រើនតែត្រូវ ៗ ល្អ ៗ ។ ដូច្នេះ ការហាត់មើលចិត្តរបស់ខ្លួនឲ្យស្គាល់ខ្លួនឯង ជាឧបាយមួយដ៏ប្រសើរ ជួយអប់រំចិត្ត ជួយសាងខ្លួន ឲ្យកាន់តែបានល្អឡើង ៗ ។

ម្យ៉ាងទៀត ភិក្ខុ កាលបើបានដឹងច្បាស់ថា ចិត្ត ជាធម្មជាត មិន

ទៀងទាត់ ស្ថិតស្ថេរ រេតាមអារម្មណ៍ ប្រែប្រួល កើត រលត់ៗ មិនឈប់ឈរដូចនេះ ក៏មិនសំគាល់ថា ជា សត្វ បុគ្គល យើង គេ ហើយក៏ មិនមានតណ្ហា ទិដ្ឋិ (មានះ) និងឧបាទាន សេចក្តី ប្រកាន់មាំនូវអ្វីៗ ក្នុងលោកឡើយ ។

## ធម្មានុបស្សនាសតិប្បដ្ឋាន

❁❁❁

ធម៌ ក្នុងសតិប្បដ្ឋាន មាន ៥ យ៉ាង គឺៈ

**១-នីវរណបព្វៈ ២-ខន្ធបព្វៈ ៣-អាយតនបព្វៈ ៤-ពោជ្ឈង្គបព្វៈ ៥-សច្ចបព្វៈ ។**

### នីវរណបព្វៈ

●●●

ភិក្ខុ ពិចារណាឃើញរឿយ ៗ នូវធម៌ ក្នុងធម៌ទាំងឡាយ គឺ នីវរណធម៌ ៥ យ៉ាង ទោះ កាមច្ឆន្ទ ព្យាបាទ... មាននៅក្នុង សន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា កាមច្ឆន្ទ ព្យាបាទ... មាននៅ ក្នុងចិត្តរបស់អាត្មាអញ, ទោះ កាមច្ឆន្ទ ព្យាបាទ... មិនមាននៅ ក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា កាមច្ឆន្ទ ព្យាបាទ... មិន មាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ, ទោះ កាមច្ឆន្ទ ព្យាបាទ.. ដែលមិនទាន់កើតឡើង កើតឡើងបាន ដោយហេតុណា ក៏ដឹង ច្បាស់នូវហេតុនោះផង, ការលះបង់នូវ កាមច្ឆន្ទ ព្យាបាទ......

ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង, កាមច្ឆន្ទ ព្យាបាទ... ដែលលះបង់បានហើយ មិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។

ភិក្ខុ ពិចារណាឃើញរឿយ ៗ នូវធម៌ ក្នុងធម៌ទាំងឡាយ (នីវរណធម៌) ខាងក្នុង... ខាងក្រៅ... ទាំងខាងក្នុងទាំងខាងក្រៅ ។ ភិក្ខុ ពិចារណាឃើញរឿយ ៗ នូវការប្រជុំកើតឡើង និង ការរលត់ ក្នុងធម៌ទាំងឡាយ ។ល។

សតិ របស់ភិក្ខុនោះ តាំងមាំថា ធម៌ មានមែន គ្រាន់តែដើម្បីជាទីដឹង ដើម្បីជាទីរលឹក មិនមានជា សត្វ បុគ្គល យើង គេទេ ។

ភិក្ខុនោះ មិនមាន តណ្ហា ទិដ្ឋិ (មានះ) និង ឧបាទាន សេចក្តីប្រកាន់មាំនូវអ្វី ៗ ក្នុងលោកឡើយ ។

ភិក្ខុ ពិចារណាឃើញរឿយ ៗ នូវធម៌ ក្នុងធម៌ទាំងឡាយ យ៉ាងនេះឯង ។

ខត្លួសង្កេត :

ក្នុងចិត្តានុបស្សនាសតិប្បដ្ឋាន គ្រាន់តែដឹងច្បាស់ថា ចិត្តប្រកបដោយ រាគៈ ទោសៈ មោហៈ ជាដើម ប៉ុណ្ណឹង ទុកជាបានការហើយ ។ ប៉ុន្តែ ក្នុង ធម្មានុបស្សនាសតិប្បដ្ឋាន (នីវរណបព្វៈ)

ជ្រាលជ្រៅជាង គឺ ត្រូវដឹងច្បាស់ថា ចិត្តប្រកបដោយ កាមច្ឆន្ទ... ផង ត្រូវដឹងច្បាស់នូវហេតុដែល កាមច្ឆន្ទ... កើតឡើងផង ត្រូវដឹងច្បាស់នូវការលះបង់ កាមច្ឆន្ទ... (មួយរយៈ) ផង ត្រូវដឹងច្បាស់នូវការរំលត់ផាច់ខាត(ជា សមុច្ឆេទ) នូវកាមច្ឆន្ទ... ផង ។ នេះ ជាព្រំដែន នៃ ចិត្តានុបស្សនាសតិប្បដ្ឋាន និង ធម្មានុបស្សនាសតិប្បដ្ឋាន ប៉ុន្តែ សំរាប់ការអនុវត្ត គេអាចបញ្ចូលគោលធម៌ទាំងពីរនេះ ជាមួយគ្នាបាន ។

**ខន្ធបព្វៈ**

❀❀❀

ភិក្ខុ ក្នុងសាសនានេះ ពិចារណាឃើញរឿយ ។ នូវធម៌ ក្នុងធម៌ទាំងឡាយ គឺ ឧបាទានក្ខន្ធ ៥ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ។

ភិក្ខុ ពិចារណាឃើញរឿយ ។ នូវរូបដូច្នេះ នូវការប្រជុំកើតឡើង នៃ រូបដូច្នេះ នូវការរលត់ទៅនៃរូបដូច្នេះ ។ ភិក្ខុ ពិចារណាឃើញរឿយ ។ នូវវេទនា ដូច្នេះ នូវការប្រជុំកើតឡើង នៃ វេទនាដូច្នេះ នូវការរលត់ទៅ នៃ វេទនាដូច្នេះ ។ល។

ភិក្ខុ ពិចារណាឃើញរឿយ ។ នូវធម៌ ក្នុងធម៌ទាំងឡាយ គឺ (ខន្ធ ៥) ខាងក្នុង... ខាងក្រៅ... ទាំងខាងក្នុងទាំងខាងក្រៅ ។

ភិក្ខុ ពិចារណាឃើញរឿយ។នូវការប្រជុំកើតឡើងនៃរូប នូវការរលត់ទៅនៃរូប នូវការប្រជុំកើតឡើងនិងការរលត់ទៅនៃរូប។ល។

សតិ របស់ភិក្ខុនោះ តាំងមាំថា រូបមានមែន គ្រាន់តែដើម្បីជាទីដឹង គ្រាន់តែដើម្បីជាទីរលឹក មិនមានជា សត្វ បុគ្គល យើង គេ ទេ ។

ភិក្ខុនោះ មិនមាន តណ្ហា ទិដ្ឋិ (មានះ) និង ឧបាទាន សេចក្ដីប្រកាន់មាំនូវអ្វី ។ ក្នុងលោកឡើយ ។

វេទនា សញ្ញា សង្ខារ វិញ្ញាណ មានអត្ថន័យ ដែលគប្បីយល់ និង គប្បីពិចារណាបដិបត្តិ ដូចគ្នានឹងរូបដែរ ។

ភិក្ខុ ពិចារណាឃើញរឿយ ។ នូវធម៌ ក្នុងធម៌ទាំងឡាយ គឺ ឧបាទានក្ខន្ធ ៥ យ៉ាងនេះឯង ។

ខគ្គរសង្កេត :

ក្នុងបទ ឧទ្ទេសនាមថា ឧបាទានក្ខន្ធ ៥ ប៉ុន្តែ ក្នុងសេចក្ដីអធិប្បាយថាត្រឹមតែ ខន្ធ ៥ ។ ក្នុងខន្ធមួយ។ អ្នកបដិបត្តិ គប្បីពិចារណា ៣ ចំណុច គឺ ១-រូបដូចម្ដេច ២-ការប្រជុំកើតឡើងនៃរូបដូចម្ដេច ៣-ការរលត់ទៅនៃរូបដូចម្ដេច ។ ឧ. រូប គឺជាធាតុ ៤ ដី ទឹក ភ្លើង ខ្យល់ ។ រូប កើតឡើងអាស្រ័យអាហារ ។ អាហាររលត់ រូបក៏រលត់ ។ វេទនា គឺការទទួលដឹងសុខ-ទុក្ខ មិនទុក្ខមិនសុខ ។ សញ្ញា គឺការកត់ចំណាំ រូប សម្លេង... វែង ខ្លី ខ្មៅ ស ជាដើម ។ សង្ខារ គឺ ការនឹកគិត ស្រឡាញ់ ស្អប់

ធ្វើបុណ្យ ធ្វើបាប ជាដើម ។ វេទនា សញ្ញា សង្ខារ កើតឡើង អាស្រ័យផស្សៈ ។ ផស្សៈ រលត់ វេទនា សញ្ញា សង្ខារ ក៏រលត់ ។ វិញ្ញាណ គឺការដឹងអាស្រ័យអាយតនៈខាងក្នុង (ចក្ខុ..) មានចក្ខុវិញ្ញាណជាដើម ។ វិញ្ញាណ កើតឡើងអាស្រ័យ នាម និង រូប ។ នាម និងរូប រលត់ វិញ្ញាណ ក៏រលត់ ។ នេះ ជាសេចក្ដីសង្ខេប នៃ ចំណុចទាំង ៣ នោះ អ្នកចង់ដឹងពិស្ដារ គប្បីសិក្សាតាមអធ្យាស្រ័យ ថែមទៀតចុះ ។

## អាយតនបញ្ច

❀❀❀

ភិក្ខុ ពិចារណាឃើញរឿយ ៗ នូវធម៌ ក្នុងធម៌ទាំងឡាយ គឺ អាយតនៈខាងក្នុង ៦ និង អាយតនៈខាងក្រៅ ៦ ។

អាយតនៈខាងក្នុង ៦

| | |
|---|---|
| ១-ចក្ខុ | ភ្នែក |
| ២-សោត | ត្រចៀក |
| ៣-ឃាន | ច្រមុះ |
| ៤-ជិវ្ហា | អណ្ដាត |
| ៥-កាយ | កាយ |
| ៦-មនះ | ចិត្ត ។ |

អាយតនៈខាងក្រៅ ៦

១-រូប　　　　　　រូប

២-សទ្ទ　　　　　　សម្លេង

៣-គន្ធ　　　　　　ក្លិន

៤-រស　　　　　　រស

៥-ផោដ្ឋព្វ　　　　　វត្ថុដែលប៉ះកាយ

៦-ធម្ម ឬធម្មារម្មណ៍　អារម្មណ៍ដែលចិត្តនឹកគិត ។

ភិក្ខុ ក្នុងសាសនានេះ ដឹងច្បាស់នូវចក្ខុផង ដឹងច្បាស់នូវរូបផង ដឹងច្បាស់នូវ **សញ្ញោជនៈ**[១០] ដែលកើតឡើងអាស្រ័យចក្ខុ និងរូបទាំងពីរនោះប៉ះគ្នាផង ដឹងច្បាស់នូវហេតុដែល **សញ្ញោជនៈ** មិនទាន់កើតឡើង កើតឡើងផង ដឹងច្បាស់នូវការលះបង់ (មួយរយៈ) នូវ **សញ្ញោជនៈ**ផង ដឹងច្បាស់នូវការរំលត់ដាច់ខាត (សមុច្ឆេទ) នូវ **សញ្ញោជនៈ** ផង ។ ភិក្ខុ ដឹងច្បាស់នូវ សោត ផង ដឹងច្បាស់នូវ សទ្ទ ផង ដឹងច្បាស់នូវ **សញ្ញោជនៈ** ដែលកើតឡើងអាស្រ័យ សោត និងសទ្ទ ទាំងពីរនោះប៉ះគ្នាផង ។ល។ គប្បីយល់

---

[១០]-សញ្ញោជនៈ កិលេសដែលចងសត្វទុកក្នុងភពមាន ១០ គឺ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស កាមច្ឆន្ទ ព្យាបាទ រូបរាគ អរូបរាគ មានៈ ឧទ្ធច្ចៈ អវិជ្ជា ។

ដូចៗគ្នានឹងចក្ខុនោះផងចុះ ។

ភិក្ខុ ពិចារណាឃើញរឿយ ៗ នូវធម៌ ក្នុងធម៌ទាំងឡាយ (អាយតនៈខាងក្នុង ៦ និង អាយតនៈខាងក្រៅ ៦) ខាងក្នុង... ខាងក្រៅ... ទាំងខាងក្នុង និង ទាំងខាងក្រៅ ។

ភិក្ខុ ពិចារណាឃើញរឿយ ៗ នូវការប្រជុំកើតឡើង... នូវការរលត់ទៅ... ទាំងនូវការប្រជុំកើតឡើង ទាំងនូវការរលត់ទៅ នៃអាយតនៈខាងក្នុង ៦ និង អាយតនៈខាងក្រៅ ៦ ។

សតិ របស់ភិក្ខុនោះ តាំងមាំថា អាយតនៈខាងក្នុង ៦ និង អាយតនៈខាងក្រៅ ៦ មានមែន គ្រាន់តែដើម្បីជាទីដឹង គ្រាន់តែដើម្បីជាទីរលឹក មិនមានជា សត្វ បុគ្គល យើង គេ ទេ ។

ភិក្ខុនោះ មិនមាន តណ្ហា ទិដ្ឋិ (មានៈ) និង ឧបាទាន សេចក្ដីប្រកាន់មាំនូវអ្វី ៗ ក្នុងលោកឡើយ ។

ភិក្ខុ ពិចារណាឃើញរឿយ ៗ នូវធម៌ ក្នុងធម៌ទាំងឡាយ គឺ អាយតនៈខាងក្នុង និង អាយតនៈខាងក្រៅ យ៉ាងនេះឯង ។

ខគ្គសង្កេត :

អាយតនៈ កន្លែងតឲ្យកើត កើតអ្វី ? កើតឃើញ កើតឮ កើតស្អប់ កើតស្រឡាញ់ កើតអញ កើតឯង កើតកិលេសផ្សេងៗ តណ្ហា ទិដ្ឋិ មានៈ សញ្ញោជនៈ អវិជ្ជា ។ល។

អាយតនៈខាងក្នុង ខាងក្នុងគឺជាប់នឹងខ្លួនយើង ឬ ជារបស់សំខាន់ច្រើនជាង អាយតនៈខាងក្រៅ ខាងក្រៅគឺមិនជាប់នឹងខ្លួនយើង ឬ ជារបស់សំខាន់តិចជាង ។

ភិក្ខុ (អ្នកបដិបត្តិធម៌) គប្បីដឹងច្បាស់ ៦ ចំណុច គឺ ១-ដឹងច្បាស់នូវចក្ខុផង ២-ដឹងច្បាស់នូវរូបផង ៣-ដឹងច្បាស់នូវសញ្ញោជនៈ ដែលកើតឡើងអាស្រ័យចក្ខុ និង រូបទាំងពីរនោះប៉ះគ្នាផង ៤-ដឹងច្បាស់នូវហេតុដែល សញ្ញោជនៈ មិនទាន់កើតឡើងកើតឡើងផង ៥-ដឹងច្បាស់នូវការលះបង់ (មួយរយៈ) នូវសញ្ញោជនៈផង ៦-ដឹងច្បាស់នូវការរំលត់ផាច់ខាត (សមុច្ឆេទ) នូវសញ្ញោជនៈផង ។

ភិក្ខុ គប្បីដឹងច្បាស់ថា ចក្ខុ មិនមែនសាច់ភ្នែកទេ សំដៅយក ចក្ខុបសាទ គឺជាវត្ថុសំរាប់ជួយឲ្យមើលឃើញ ប៉ុន្តែ មិនមែនជាអ្នកឃើញទេ អ្នកឃើញគឺ ចក្ខុវិញ្ញាណ ឃើញអ្វី ឃើញរូប គឺឃើញរូបពណ៌ ។

អាយតនៈឯទៀត សោត ឃាន ។ល។ សទ្ទ គន្ធ ។ល។ មានអត្ថន័យ ដែលគប្បីសិក្សាបដិបត្តិ ឲ្យដឹងច្បាស់ ដូច ចក្ខុ និង រូប នោះដែរ ។

អាយតនៈទាំងអស់ ទាំងខាងក្នុងទាំងខាងក្រៅ មានមែនគ្រាន់តែដើម្បីជាទីដឹង គ្រាន់តែដើម្បីជាទីរលឹក មិនមានជា សត្វ

បុគ្គល យើង គេ ទេ ។

ភិក្ខុនោះ មិនគប្បីមាន តណ្ហា ទិដ្ឋិ (មានះ) និង ឧបាទាន សេចក្តីប្រកាន់មាំនូវអ្វីៗ ក្នុងលោកឡើយ ។

ភិក្ខុ ពិចារណាឃើញរឿយ ៗ នូវធម៌ ក្នុងធម៌ទាំងឡាយ គឺ អាយតនៈខាងក្នុង ៦ អាយតនៈខាងក្រៅ ៦ យ៉ាងនេះឯង ។

## ពោជ្ឈង្គបព្វៈ

៣❀៧

ភិក្ខុ ពិចារណាឃើញរឿយ ៗ នូវធម៌ ក្នុងធម៌ទាំងឡាយ គឺ ពោជ្ឈង្គ អង្គធម៌ជាគ្រឿងត្រាស់ដឹង ៧ យ៉ាង គឺ :

**១-សតិសម្ពោជ្ឈង្គ** អង្គធម៌ជាគ្រឿងត្រាស់ដឹង គឺសតិ។

**២-ធម្មវិចយសម្ពោជ្ឈង្គ** អង្គធម៌ជាគ្រឿងត្រាស់ដឹង គឺ ការពិចារណាធម៌ ។

**៣-វិរិយសម្ពោជ្ឈង្គ** អង្គធម៌ជាគ្រឿងត្រាស់ ដឹង គឺ សេចក្តីព្យាយាម ។

**៤-បីតិសម្ពោជ្ឈង្គ** អង្គធម៌ជាគ្រឿងត្រាស់ ដឹង គឺ សេចក្តីឆ្អែតចិត្ត ។

**៥-បស្សទ្ធិសម្ពោជ្ឈង្គ** អង្គធម៌ជាគ្រឿងត្រាស់ ដឹង គឺ សេចក្តីស្ងប់កាយស្ងប់ចិត្ត ។

**៦-សមាធិសម្ពោជ្ឈង្គ** អង្គធម៌ជាគ្រឿងត្រាស់ដឹង

គឺ ការតាំងចិត្តមាំ ។

**៧-ឧបេក្ខាសម្ពោជ្ឈង្គ** អង្គធម៌ជាគ្រឿងត្រាស់ដឹង

គឺ ការតាំងចិត្តជាកណ្ដាល ។

ភិក្ខុ ក្នុងសាសនានេះ ទោះសតិសម្ពោជ្ឈង្គ មាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គ មាននៅក្នុងសន្តានចិត្តនៃអាត្មាអញ, ទោះ សតិសម្ពោជ្ឈង្គ មិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គ មិនមាននៅក្នុងសន្តានចិត្តនៃអាត្មាអញ, ទោះ សតិសម្ពោជ្ឈង្គ មិនទាន់កើតឡើង កើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង, ការចំរើនឡើងបរិបូណ៌នៃសតិសម្ពោជ្ឈង្គ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹច្បាស់នូវហេតុនោះផង ។

ភិក្ខុ ពិចារណាឃើញរឿយ ៗ នូវធម៌ក្នុងធម៌ទាំងឡាយ (គឺ ពោជ្ឈង្គ) ខាងក្នុង ខាងក្រៅ ទាំងខាងក្នុងទាំងខាងក្រៅ ។ ភិក្ខុ ពិចារណាឃើញរឿយ ៗ នូវការប្រជុំកើតឡើង ការរលត់ទៅ ទាំងការប្រជុំកើតឡើង ទាំងការរលត់ទៅ ក្នុងធម៌ទាំងឡាយ ។

សតិ របស់ភិក្ខុនោះ តាំងមាំថា ធម៌មានមែន គ្រាន់តែ ដើម្បីជាទីដឹង ដើម្បីជាទីរលឹក មិនមានជា សត្វ បុគ្គល យើង គេ ទេ ។

ភិក្ខុនោះ មិនមាន តណ្ហា ទិដ្ឋិ(មានៈ) និង ឧបាទាន សេចក្ដីប្រកាន់មាំនូវអ្វីៗក្នុងលោកឡើយ ។

ភិក្ខុ ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ យ៉ាងនេះឯង ។

**ធម្មវិចយសម្ពោជ្ឈង្គ វីរិយសម្ពោជ្ឈង្គ បីតិសម្ពោជ្ឈង្គ បស្សទ្ធិសម្ពោជ្ឈង្គ សមាធិសម្ពោជ្ឈង្គ ឧបេក្ខាសម្ពោជ្ឈង្គ** មានអត្ថន័យដែលគប្បី សិក្សាបដិបត្តិ ដូចគ្នានឹង សតិសម្ពោជ្ឈង្គនោះដែរ ។

ខគួរសង្កេត :

១- ភិក្ខុ (អ្នកបដិបត្តិធម៌)

-ត្រូវអាស្រ័យនូវសីល តាំងនៅក្នុងសីលហើយ ទើបចំរើន ពោជ្ឈង្គ ។

-ត្រូវចំរើន ពោជ្ឈង្គ អាស្រ័យការស្ងប់ស្ងាត់ អាស្រ័យការប្រាសចាកតម្រេក អាស្រ័យការរលត់ អាស្រ័យការបង្អោនទៅរកការលះបង់ ដូចបានពោលហើយ ក្នុងធម៌ខាងដើម ។

២-សម័យដែលត្រូវចំរើន ពោជ្ឈង្គ

-សម័យណា ចិត្តរួញរា (លីនចិត្ត ឬ ចិត្តប្រកបដោយថីនមិទ្ធៈ) សម័យនោះ ជាកាលមិនគួរនឹងចំរើន បស្សទ្ធិសម្ពោជ្ឈង្គ

សមាធិសម្ពោជ្ឈង្គ ឧបេក្ខាសម្ពោជ្ឈង្គ ។

-ក្នុងសម័យណា ចិត្តរួញរា សម័យនោះ ជាកាលសមគួរនឹងចំរើន ធម្មវិចយសម្ពោជ្ឈង្គ វីរិយសម្ពោជ្ឈង្គ បីតិសម្ពោជ្ឈង្គ ។

-សម័យណា ចិត្តរាយមាយ (ឧទ្ធច្ច) សម័យនោះ ជាកាលមិនសមគួរនឹងចំរើន ធម្មវិចយសម្ពោជ្ឈង្គ វីរិយសម្ពោជ្ឈង្គ បីតិសម្ពោជ្ឈង្គ ។

-ក្នុងសម័យណា ចិត្តរាយមាយ សម័យនោះ ជាកាលសមគួរនឹងចំរើន បស្សទ្ធិសម្ពោជ្ឈង្គ សមាធិសម្ពោជ្ឈង្គ ឧបេក្ខាសម្ពោជ្ឈង្គ ។

ម្នាលភិក្ខុទាំងឡាយ តថាគត ពោលថា សតិ ជាធម៌សម្រេចប្រយោជន៍គ្រប់យ៉ាង ។ បានសេចក្តីថា សតិ ត្រូវប្រើគ្រប់ពេល និង គ្រប់អង្គនៃ ពោជ្ឈង្គ ទាំងអស់ ឬថា សតិសម្ពោជ្ឈង្គ ចំរើនសម័យណាក៏បាន ឥតមានទំនាស់អ្វីឡើយ ។

## ៣-អាហាររបស់ ពោជ្ឈង្គ

### ក-តាមន័យក្នុងបាលី

1-ធម៌ជាទីតាំងនៃ សតិសម្ពោជ្ឈង្គ រមែងមាន ការធ្វើទុកក្នុងចិត្តត្រូវទំនង (យោនិសោមនសិការៈ) និង ការធ្វើឲ្យច្រើននូវធម៌នោះ នេះជាអាហារនាំ សតិសម្ពោជ្ឈង្គ ដែលមិនទាន់កើត ឲ្យ

កើតឡើង ដែលកើតឡើងហើយ ឲ្យរឹតតែចំរើនពេញលេញ ឡើងបាន ។

2-ធម៌ជាកុសល និង អកុសល ធម៌មានទោស និង មិនមានទោស ធម៌ថោកទាប និង ប្រណីត ធម៌ខ្មៅ និង ស រមែងមានការធ្វើទុកក្នុងចិត្តត្រូវទំនង និង ការធ្វើឲ្យច្រើននូវធម៌នោះ នេះជាអាហារនាំ ធម្មវិចយសម្ពោជ្ឈង្គ ដែលមិនទាន់កើត ឲ្យកើតឡើង ដែលកើតឡើងហើយ ឲ្យរឹតតែចំរើនពេញលេញឡើងបាន ។

3-**អារព្ភធាតុ** ធាតុផ្តួចផ្តើម **និក្កមធាតុ** ធាតុព្យាយាម **បរក្កមធាតុ** ធាតុខ្នះខ្នែង រមែងមាន ការធ្វើទុកក្នុងចិត្តត្រូវទំនង និងការធ្វើឲ្យច្រើននូវធម៌នោះ នេះជាអាហារនាំ វីរិយសម្ពោជ្ឈង្គ ដែលមិនទាន់កើត ឲ្យកើតឡើង ដែលកើតឡើងហើយ ឲ្យរឹតតែចំរើនពេញលេញឡើងបាន ។

4-ធម៌ជាទីតាំងនៃ បីតិសម្ពោជ្ឈង្គ រមែងមាន ការធ្វើទុកក្នុងចិត្តត្រូវទំនង និង ការធ្វើឲ្យច្រើននូវធម៌នោះ នេះជាអាហារនាំ បីតិសម្ពោជ្ឈង្គ ដែលមិនទាន់កើត ឲ្យកើតឡើង ដែលកើតឡើងហើយ ឲ្យរឹតតែចំរើនពេញលេញឡើងបាន ។

5-**កាយបស្សទ្ធិ** សេចក្តីស្ងប់កាយ **ចិត្តបស្សទ្ធិ** សេចក្តីស្ងប់ចិត្ត រមែងមាន ការធ្វើទុកក្នុងចិត្តត្រូវទំនង និង ការធ្វើឲ្យច្រើននូវធម៌នោះ នេះជាអាហារនាំ បស្សទ្ធិសម្ពោជ្ឈង្គ ដែលមិន

ទាន់កើត ឲ្យកើតឡើង ដែលកើតឡើងហើយ ឲ្យរីតតែចំរើនពេញលេញឡើងបាន ។

6-**សមាធិនិមិត្ត** ហេតុនៃការតាំងចិត្តមាំ **អព្យគ្គនិមិត្ត** ហេតុនៃការមិនរាយមាយ រមែងមាន ការធ្វើទុកក្នុងចិត្ត ត្រូវទំនង និង ការធ្វើឲ្យច្រើននូវធម៌នោះ នេះជាអាហារនាំ សមាធិ-សម្ពោជ្ឈង្គ ដែលមិនទាន់កើត ឲ្យកើតឡើង ដែលកើតឡើងហើយ ឲ្យរឹតតែចំរើនពេញលេញឡើងបាន ។

7-ធម៌ជាទីតាំងនៃ ឧបេក្ខាសម្ពោជ្ឈង្គ រមែងមាន ការធ្វើទុកក្នុងចិត្តត្រូវទំនង និង ការធ្វើឲ្យច្រើននូវធម៌នោះ នេះជាអាហារនាំ ឧបេក្ខាសម្ពោជ្ឈង្គ ដែលមិនទាន់កើត ឲ្យកើតឡើង ដែលកើតឡើងហើយ ឲ្យរឹតតែចំរើនពេញលេញឡើងបាន ។

ខ-តាមន័យក្នុង អដ្ឋកថា

-ធម៌ជាហេតុនាំឲ្យកើត សតិសម្ពោជ្ឈង្គ និង ជួយធ្វើសតិសម្ពោជ្ឈង្គ ឲ្យរឹតតែចំរើនឡើងមាន ៤ គឺ :

1-ត្រូវមាន សតិ សម្បជញ្ញៈ គ្រប់ឥរិយាបថ គ្រប់ពេលវេលា ។

2-ត្រូវវៀរចាកបុគ្គលអ្នកភ្លេចស្មារតី ។

3-ត្រូវសេពគប់បុគ្គលអ្នកមានស្មារតីមាំមួន ។

4-ត្រូវបង្អោនចិត្តទៅក្នុង សតិសម្ពោជ្ឈង្គៈ ។

-ធម៌ជាហេតុនាំឲ្យកើត ធម្មវិចយសម្ពោជ្ឈង្គ និង ជួយធ្វើធម្មវិចយសម្ពោជ្ឈង្គ ឲ្យរឹតតែចំរើនឡើង មាន ៧ គឺ :

1-ការសាកសួរ

2-ការធ្វើវត្ថុខាងក្នុង គឺខ្លួនប្រាណយើង និង វត្ថុខាងក្រៅមាន ស្បង់ ចីពរ ជាដើម ឲ្យស្អាត ។

3-ប្រមូលឥន្ទ្រិយទាំង ៥ មានសទ្ធិន្ទ្រិយ ជាដើម ឲ្យស្មើគ្នា ។

4-វៀរចាកបុគ្គលដែលអាប់ឥតប្រាជ្ញា ។

5-គប់រកបុគ្គលដែលមានប្រាជ្ញា ។

6-ពិចារណាធម៌ដោយបញ្ញាដ៏ជ្រាលជ្រៅ ។

7-បង្អោនចិត្តទៅក្នុង ធម្មវិចយសម្ពោជ្ឈង្គ ។

-ធម៌ជាហេតុនាំឲ្យកើត វីរិយសម្ពោជ្ឈង្គ និង ជួយធ្វើវីរិយសម្ពោជ្ឈង្គ ឲ្យរឹតតែចំរើនឡើង មាន ១១ គឺ :

1-ពិចារណាឃើញភ័យក្នុងអបាយ ។

2-ឃើញអានិសង្សនៃការព្យាយាម ។

3-ពិចារណាឃើញផ្លូវដែលគួរទៅ ។

4-គោរពចំពោះការត្រាច់បិណ្ឌបាត ។

5-ពិចារណាឃើញភាវៈជាធំនៃមរតក ។

6-ពិចារណាឃើញភាវៈជាធំ នៃ ព្រះសាស្ដា ។

7-ពិចារណាឃើញភារៈជាធំ នៃ ជាតិ ។

8-ពិចារណាឃើញភារៈជាធំ នៃ សព្រហ្មចារី ។

9-វៀរចាកបុគ្គលខ្ជិលច្រអូស ។

10-គប់រកបុគ្គលដែលមានព្យាយាម ។

11-បង្អោនចិត្តទៅក្នុង វីរិយសម្ពោជ្ឈង្គ ។

-ធម៌ជាហេតុនាំឲ្យកើត បីតិសម្ពោជ្ឈង្គ និង ជួយធ្វើបីតិសម្ពោជ្ឈង្គ ឲ្យរឹតតែចំរើនឡើង មាន ១១ គឺ :

1-រលឹកគុណព្រះពុទ្ធ ។

2-រលឹកគុណព្រះធម៌ ។

3-រលឹកគុណព្រះសង្ឃ ។

4-រលឹកដល់ សីល ។

5-រលឹកដល់ បរិច្ចាគ ។

6-រលឹកដល់ធម៌នាំឲ្យកើតជាទេវតា ។

7-រលឹកដល់ព្រះនិព្វាន ។

8-វៀរចាកបុគ្គលមិនស្អាត ។

9-គប់រកបុគ្គលស្អាត ។

10-ពិចារណាធម៌ដែលគួរឲ្យជ្រះថ្លា ។

11-បង្អោនចិត្តទៅក្នុង បីតិសម្ពោជ្ឈង្គ ។

-ធម៌ជាហេតុនាំឲ្យកើត បស្សទ្ធិសម្ពោជ្ឈង្គ និង ជួយធ្វើបស្សទ្ធិសម្ពោជ្ឈង្គ ឲ្យរីតតែចំរើនឡើង មាន ៧ គឺ :

1-ត្រូវការភោជនថ្លៃថ្លា ។

2-ត្រូវការរដូវសប្បាយ ។

3-ត្រូវការ ឥរិយាបថសប្បាយ ។

4-មានព្យាយាមជាកណ្តាល ។ ។

5-វៀរចាកបុគ្គលមានកាយមិនស្ងប់ស្ងាត់ ។

6-គប់រកបុគ្គលមានកាយស្ងប់ស្ងាត់ ។

7-បង្អោនចិត្តទៅក្នុង បស្សទ្ធិសម្ពោជ្ឈង្គ ។

-ធម៌ជាហេតុនាំឲ្យកើត សមាធិសម្ពោជ្ឈង្គ និង ជួយធ្វើសមាធិសម្ពោជ្ឈង្គ ឲ្យរីតតែចំរើនឡើង មាន ១១ គឺ :

1-ធ្វើវត្ថុខាងក្នុង និង វត្ថុខាងក្រៅឲ្យស្អាត ។

2-ប្រមូលឥន្ទ្រិយទាំង ៥ ឲ្យស្មើគ្នា ។

3-ឈ្លាសក្នុងកសិណនិមិត្ត ។

4-លើកចិត្ត(ផ្គង)ឡើងតាមសម័យ ។

5-សង្កត់សង្កិនចិត្តតាមសម័យ ។

6-ធ្វើចិត្តឲ្យរីករាយតាមសម័យ ។

7-ធ្វើចិត្តឲ្យតក់ស្លុត(ចំពោះសង្វេគវត្ថុ៨ប្រការ) តាមសម័យ

8-តាំងចិត្តជាកណ្តាល។ ។

9-វៀរចាកបុគ្គលដែលមានចិត្តមិនតាំងមាំ ។

10-គប់រកបុគ្គលដែលមានចិត្តតាំងមាំ ។

11-បង្អោនចិត្តទៅក្នុង សមាធិសម្ពោជ្ឈង្គ ។

-ធម៌ជាហេតុនាំឲ្យកើត ឧបេក្ខាសម្ពោជ្ឈង្គ និង ជួយធ្វើឧបេក្ខាសម្ពោជ្ឈង្គ ឲ្យរឹតតែចំរើនឡើង មាន៥ គឺ :

1-ធ្វើចិត្តឲ្យតាំងនៅជាកណ្តាលចំពោះ សត្វ ។

2-ធ្វើចិត្តឲ្យតាំងនៅជាកណ្តាលចំពោះ សង្ខារ ។

3-វៀរចាកបុគ្គលដែលមានចិត្តជាប់ជំពាក់ចំពោះ សត្វ និង សង្ខារ ។

4-គប់រកបុគ្គលមានចិត្តជាកណ្តាលចំពោះ សត្វ និងសង្ខារ។

៥-បង្អោនចិត្តទៅក្នុង ឧបេក្ខាសម្ពោជ្ឈង្គ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលណា បានប្រារព្ធ ពោជ្ឈង្គ ៧ ហើយ បុគ្គលនោះ ឈ្មោះថា បានប្រារព្ធ អរិយមគ្គ ប្រព្រឹត្តទៅដើម្បីអស់ទុក្ខដោយប្រពៃ ។

-ពោជ្ឈង្គ ៧ ញ៉ាំង វិជ្ជា និង វិមុត្តិ ឲ្យពេញលេញ។

-សតិប្បដ្ឋាន ៤ ញ៉ាំង ពោជ្ឈង្គ ៧ ឲ្យពេញលេញ ។

-សុចរិត ៣ ញ៉ាំង សតិប្បដ្ឋាន ៤ ឲ្យពេញលេញ ។

-ឥន្ទ្រិយសំវរៈ ញ៉ាំង សុចរិត ៣ ឲ្យពេញលេញ ។

## ប្រការសំខាន់គឺ ឥន្ទ្រិយសំវរៈ

ឥន្ទ្រិយសំវរៈ ⟶ សុចរិត ៣ ⟶ សតិប្បដ្ឋាន ៤

សតិប្បដ្ឋាន ៤ ⟶ ពោជ្ឈង្គ ៧ ⟶ វិជ្ជា និង វិមុត្តិ ។

## សច្ចបព្វៈ

ភិក្ខុ ពិចារណាឃើញរឿយ ៗ នូវធម៌ ក្នុងធម៌ទាំងឡាយ គឺ អរិយសច្ច ៤ :

១-ទុក្ខ អរិយសច្ច របស់ពិតដ៏ប្រសើរគឺ ទុក្ខ ។

២-ទុក្ខសមុទយ អរិយសច្ច របស់ពិតដ៏ប្រសើរ គឺ ហេតុឲ្យទុក្ខកើត ។

៣-ទុក្ខនិរោធ អរិយសច្ច របស់ពិតដ៏ប្រសើរ គឺ ការរលត់ទុក្ខ ។

៤-ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ច របស់ពិតដ៏ប្រសើរ គឺ ផ្លូវបដិបត្តិ នាំឲ្យដល់ការរលត់ទុក្ខ[១១]។

### ទុក្ខសច្ច មាន ១២ កង

១-**ជាតិ** ការកើត

២-**ជរា** សេចក្ដីចាស់គ្រាំគ្រា

---

[១១]-ហៅខ្លីថា ទុក្ខសច្ច សមុទយសច្ច និរោធសច្ច មគ្គសច្ច ។

៣-**មរណា** សេចក្ដីស្លាប់

៤-**សោក** សេចក្ដីក្រៀមក្រំ

៥-**បរិទេវ** សេចក្ដីខ្សឹកខ្សួល

៦-**ទុក្ខ** សេចក្ដីលំបាកកាយ

៧-**ទោមនស្ស** សេចក្ដីលំបាកចិត្ត

៨-**ឧបាយាស** សេចក្ដីតានតឹងចិត្ត

៩-**អប្បិយេហិ សម្បយោគ** ការជួបប្រសពដោយសត្វ និង សង្ខារ មិនជាទីស្រឡាញ់

១០-**បិយេហិ វិប្បយោគ** ការព្រាត់ប្រាសចាកសត្វ និង សង្ខារ ជាទីស្រឡាញ់

១១-**យម្បិច្ឆំ ន លភតិ** មិនបានតាមប្រាថ្នា

១២-**សង្ខិត្តេន បញ្ចុប្បាទាន** ពោលដោយបំព្រួញ ឧបាទានក្ខន្ធ ៥ ។

## សមុទយសច្ច មាន ៣ គឺ :

១-**កាមតណ្ហា** ចំណង់ក្នុងកាម

២-**ភវតណ្ហា** ចំណង់ក្នុងភព

៣-**វិភវតណ្ហា** ចំណង់ក្នុងការប្រាសចាកភព ។

## និរោធសច្ច

ការប្រាសចាកតម្រេក និង ការរលត់ដោយឥតមានសេសសល់ ការលះបង់ ការរលាស់ចេញ ការរួចស្រឡះ ការមិនមានអាល័យនៃតណ្ហានោះ ហៅថា និរោធសច្ច ។

## មគ្គសច្ច

ផ្លូវមួយប្រកបដោយអង្គ ៨ ដ៏ប្រសើរ ហៅថា អរិយដ្ឋង្គិកមគ្គ ឬ មគ្គសច្ច ។ អង្គ ៨ នោះគឺ :

១-**សម្មាទិដ្ឋិ** ការយល់ឃើញត្រូវ

២-**សម្មាសង្កប្បោ** សេចក្តីត្រិះរិះត្រូវ

៣-**សម្មាវាចា** ពាក្យសំដីត្រូវ

៤-**សម្មាកម្មន្តោ** ការងារត្រូវ

៥-**សម្មាអាជីវោ** ការចិញ្ចឹមជីវិតត្រូវ

៦-**សម្មាវាយាមោ** សេចក្តីព្យាយាមត្រូវ

៧-**សម្មាសតិ** ការរលឹកត្រូវ

៨-**សម្មាសមាធិ** ការតាំងចិត្តមាំត្រូវ ។

ភិក្ខុ ក្នុងសាសនានេះ ពិចារណាឃើញរឿយ ៗ នូវធម៌ ក្នុងធម៌ទាំងឡាយ ខាងក្នុង ខាងក្រៅ ទាំងខាងក្នុងទាំងខាងក្រៅ ។ ភិក្ខុ ពិចារណាឃើញរឿយ ៗ នូវការប្រជុំកើតឡើង នូវការរលត់ទៅ

ទាំងនូវការប្រជុំកើតឡើង ទាំងនូវការរលត់ទៅ ក្នុងធម៌ទាំងឡាយ។

សតិ របស់ភិក្ខុនោះ តាំងមាំថា ធម៌មានមែន គ្រាន់តែដើម្បីជាទីដឹង ដើម្បីជាទីរលឹក មិនមានជា សត្វ បុគ្គល យើង គេ ទេ ។

ភិក្ខុនោះ មិនមាន តណ្ហា ទិដ្ឋិ (មានៈ) ឧបាទាន សេចក្ដីប្រកាន់មាំនូវអ្វី។ ក្នុងលោកឡើយ ។

ភិក្ខុ ពិចារណាឃើញរឿយ។ នូវធម៌ ក្នុងធម៌ទាំងឡាយ យ៉ាងនេះឯង ។

ខគ្គរសង្កេត :

## ញាណ ៣

១-**សច្ចញាណ** ដឹងថាជារបស់ពិត ។ **ទុក្ខសច្ច** មាន ជាតិ ជាដើម ជាទុក្ខពិត ។ **សមុទយសច្ច** មានកាមតណ្ហា ជាដើម ជាហេតុនាំឲ្យទុក្ខកើតពិត **និរោធសច្ច** ការរំលត់នូវតណ្ហា ជាការរំលត់ទុក្ខពិត **មគ្គសច្ច** ផ្លូវប្រកបដោយអង្គ ៨ ដ៏ប្រសើរ ជាបដិបទានាំទៅដល់ការរំលត់ទុក្ខពិត ។

២-**កិច្ចញាណ** ដឹងកិច្ចដែលគប្បីធ្វើ ។ **ទុក្ខសច្ច** មាន កិច្ចដែលគប្បីកំណត់ដឹង **សមុទយសច្ច** មានកិច្ចដែលត្រូវលះបង់ **និរោធសច្ច** មានកិច្ចដែលត្រូវធ្វើឲ្យជាក់ច្បាស់ **មគ្គសច្ច** មានកិច្ច

ដែលត្រូវចំរើន គឺបដិបត្តិតាម ។

៣-**កតញ្ញាណ** ដឹងថាបានធ្វើហើយ ។ **ទុក្ខសច្ច** បានកំណត់ដឹងហើយ **សមុទយសច្ច** បានលះបង់ហើយ **និរោធសច្ច** បានធ្វើឲ្យជាក់ច្បាស់ហើយ **មគ្គសច្ច** បានចំរើនហើយ ។

ញាណ ឬ ញាណទស្សនៈ ៣ នេះ វិលជុំវិញ អរិយសច្ច ៤ ។ ក្នុងសច្ចមួយ មានញាណវិលជុំវិញ ៣ ហៅថា បរិវដ្ត ៣ ក្នុងសច្ច៤ មានញាណវិលជុំវិញ ១២ ហៅថា អាការៈ ១២ ។

ព្រះពុទ្ធ សម្តែងថា ដរាបណា ញាណទស្សនៈ វិលទៅមិនទាន់មាន បរិវដ្ត ៣ មិនទាន់គ្រប់ អាការៈ ១២ ដរាបនោះព្រះអង្គ មិនប្តេជ្ញាថា ជាអ្នកត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ទេ ។ លុះត្រាតែញាណទស្សនៈនេះ មានបរិវដ្ត ៣ មានអាការៈ ១២ គ្រប់បរិបូណ៌ពេលណា ពេលនោះ ទើបព្រះអង្គ ប្តេជ្ញាថា ជាអ្នកត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ។ នេះឯង ជាលក្ខណៈ នៃការត្រាស់ដឹង (ចេះដឹង) នូវអរិយសច្ច ។

សព្វថ្ងៃ បុគ្គលខ្លះ និយាយថា គេចេះដឹង គេយល់ច្បាស់នូវ អរិយសច្ច ហើយ ។ តើ គេចេះដឹងកម្រិតណា បានញាណប៉ុន្មានហើយ ។ បើគ្រាន់តែថា ចេះ ។ មិនទាន់មានញាណកើតឡើង មិនរាប់ថា ចេះដឹង ឬ ត្រាស់ដឹង តាមទស្សនៈពុទ្ធសាសនា ទេ។

## ទោសនៃការមិនដឹងច្បាស់
## នូវអរិយសច្ច

៦១❁៧

ការមិនដឹងច្បាស់ ការមិនបានត្រាស់ដឹង នូវអរិយសច្ច ធ្វើឲ្យគេវង្វេង ធ្វើឲ្យគេភាន់ច្រឡំ មិនដឹងហេតុផល មិនស្គាល់សេចក្តីពិត ជាហេតុនាំឲ្យកិលេស លោភ ទោស មោហ កើតឡើង។ អាស្រ័យដោយកិលេសនោះ ជាតិ ជរា ព្យាធិ មរណៈ កើតស្លាប់ៗ រាប់មិនអស់ វិលចុះ វិលឡើង ពីលើទៅក្រោម ពីក្រោមមកលើ ឆ្អឹងមនុស្សម្នាក់ មានគំនរធំជាងភ្នំ ទឹកភ្នែកយំ ច្រើនជាងទឹកសមុទ្ទ សេចក្តីទុក្ខលំបាក នានាប្បការ ច្រើនគណនា អញ្ញមញ្ញខាទិកា មនុស្សខាំស៊ីគ្នាដូចសត្វ បើគេភ្លាត់ធ្លាក់ទៅកើតក្នុងអបាយភូមិហើយ មិនងាយបានវិលមកកើតជាមនុស្សវិញទេ។ លោកប្រៀបទៅនឹងរឿងអណ្តើកខ្វាក់...

អណ្តើកខ្វាក់មួយ នៅក្នុងសមុទ្ទ ១០០ ឆ្នាំ ងើបអើតកមកលើផ្ទៃទឹកម្តង ។ គេបោះកងរង្វង់មូលមួយទៅក្នុងសមុទ្ទ ដើម្បីឲ្យអណ្តើកនោះ ងើបអើតកឡើង ចូលចំកងរង្វង់មូលនោះ ។ តើកាលណាទៅ អណ្តើកខ្វាក់ នឹងងើបអើតកមក ចូលចំកងរង្វង់មូលនោះ ? បើកងរង្វង់មូលក៏តូច អណ្តើកទៀតសោតក៏ខ្វាក់ សមុទ្ទក៏ធំធេង ខ្យល់បក់បោក រលកគគ្រឹកគគ្រេងយ៉ាងនេះ ។

ការវិលត្រឡប់ពីអបាយភូមិមកកើតជាមនុស្សវិញ កម្រក្រៃក្រជាង អណ្តើកខ្វាក់ ងើបអើតកមកចូលចំកងរង្វង់មូលនោះ ទៅទៀត [១២] ។

ព្រះពុទ្ធ សម្តែងថា -

ចតុន្នំ អរិយសច្ចានំ
យថាភូតំ អទស្សនា
សំសរិតំ ទីឃមទ្ធានំ
តាសុ តាស្វេវ ជាតិសុ ។

តថាគតក្តី អ្នកទាំងឡាយក្តី ដែលអន្ទោលទៅ ក្នុងជាតិទាំងឡាយនោះ ៗ អស់កាលយូរអង្វែង ព្រោះមិនបានឃើញនូវអរិយសច្ច ៤ តាមសេចក្តីពិត [១៣]។

## គុណនៃការដឹងច្បាស់
## នូវអរិយសច្ច

ការដឹងច្បាស់ ការត្រាស់ដឹង នូវអរិយសច្ច ធ្វើឲ្យគេស្គាល់

---

[១២]-សុត្តន្តបិដក សំយុត្តនិកាយ ៣៩-៤៤៤-៣០៦

[១៣]-សុត្តន្តបិដក សំយុត្តនិកាយ ៣៩-៤០០-២៦២

ច្បាស់នូវទុក្ខ នូវហេតុឲ្យទុក្ខកើត នូវការរំលត់ទុក្ខ និង នូវផ្លូវនាំឲ្យដល់ការរំលត់ទុក្ខ ។ ភិក្ខុនី វជិរា ពោលថា មានតែទុក្ខទេ កើតឡើង ស្ថិតនៅ(មួយរយៈ) និង រលត់ទៅវិញ ។ ក្រៅពីទុក្ខ គ្មានអ្វី កើតឡើងទេ... សុខគ្មានទេ គ្មានសុខកើតឡើងទេ ប៉ុន្តែកាលណា ទុក្ខរលត់ទៅ ឬ ទុក្ខមានកម្រិតចុះថយបន្តិចទៅ គេនាំគ្នាសន្មតហៅថា សុខ ។ ទុក្ខ មិនមែនមានតែផ្លូវកាយទេ ទុក្ខមានផ្លូវចិត្តផងដែរ ហើយទុក្ខផ្លូវចិត្តខ្លាំងក្លាជាងទុក្ខផ្លូវកាយ ទាំងជាហេតុនាំឲ្យទុក្ខផ្លូវកាយ វែងអន្លាយ រកទីបញ្ចប់គ្មាន ។ អ្នកមិនដឹងច្បាស់នូវអរិយសច្ច គេនាំគ្នាដោះស្រាយទុក្ខផ្លូវកាយ (ផ្នែក-សម្ភារៈ) តែម្យ៉ាង... ម្ល៉ោះហើយ ទុក្ខមិនបានធូរស្រាលប៉ុន្មានទេ នៅតែធ្ងន់ និង ក្តៅគគុកដដែល ទាំងមិនមានបែបបទថា ទុក្ខនឹងបានចប់នៅពេលណាផង ។ គ្មានទិសដៅ និង គ្មានសង្ឃឹមពិតប្រាកដទេ ។

ចំណែក អ្នកដឹងច្បាស់នូវអរិយសច្ច គេដោះស្រាយទុក្ខតាមផ្លូវកាយផង តាមផ្លូវចិត្តផង គឺថា គេស្វែងរកវិធីដោះស្រាយពីខាងក្រៅផ្សំចូលមកផង គេដោះស្រាយផ្សំពីខាងក្នុងចេញមកផង ។ ការដោះស្រាយដោយវិធីនេះ មានប្រសិទ្ធភាពល្អ ទុក្ខថយចុះតិចទៅ ៗ គេបានសុខស្រួលច្រើនឡើង ៗ ជាលំដាប់ និងមានទំនងអាចរំលត់ទុក្ខទាំងស្រុង សូម្បីតែទុក្ខច្រើននានប្បការ ក្នុង

វដ្តសំសារ ក៏អាចបញ្ចប់បាន ។ នេះ ដោយអាស្រ័យ ការដឹងច្បាស់ ការត្រាស់ដឹង នូវអរិយសច្ច ។ លោកប្រៀបធៀបបុរសមួយនាក់ ដែលត្រូវគេចាក់ ៣០០ លំពែង ក្នុង ១ ថ្ងៃ...

ព្រះពុទ្ធ សម្តែងថា -

បើមានគេនិយាយថា គេនឹងចាក់យើងដោយលំពែង ១ ថ្ងៃ ៣០០ លំពែង គឺចាក់ពេលព្រឹក ១០០ លំពែង ចាក់ពេលថ្ងៃត្រង់ ១០០ លំពែង និង ចាក់ពេលល្ងាច ១០០ លំពែង ។ គេចាក់យ៉ាងនេះ រៀងរាល់ថ្ងៃរហូតអស់រយៈពេល ១០០ ឆ្នាំ ។ លុះគេចាក់យ៉ាងនេះគ្រប់ ១០០ ឆ្នាំហើយ យើងនឹងបានត្រាស់ដឹងនូវអរិយសច្ច ។ ព្រះអង្គ ទ្រង់ត្រាស់ថា បើយើងពិតជាបានត្រាស់ដឹងនូវអរិយសច្ចមែន ទុកជាយើងមានទុក្ខវេទនាយ៉ាងខ្លាំងក្លា ដោយការចាក់ដោយលំពែងនោះយ៉ាងណាក៏ដោយ សូមឲ្យយើងព្រមឲ្យគេចាក់ចុះ ព្រោះទុក្ខវេទនាក្នុងវដ្តសំសារនេះ វាច្រើន និង ធំធេងជាងទុក្ខវេទនា ដោយការចាក់ដោយលំពែងនោះ ទៅទៀត ។ ប៉ុន្តែព្រះអង្គ មិនបានសម្តែងថា ការបានត្រាស់ដឹងនូវអរិយសច្ច ជាមួយនឹងទុក្ខវេទនា ដូចនោះទេ [១៤] ។

---

[១៤]-សុត្តន្តបិដក សំយុត្តនិកាយ ៣៩-៤១៩-២៧៨

# វិធីធ្វើឲ្យដឹងច្បាស់

## នូវអរិយសច្ច

សមាធឹ ភិក្ខវេ ភាវេថ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចំរើននូវសមាធិ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកចំរើននូវសមាធិ រមែងដឹងច្បាស់តាមសេចក្ដីពិត ។ ចុះដឹងច្បាស់អ្វី តាមសេចក្ដីពិត ។ ដឹងច្បាស់តាមសេចក្ដីពិតថា នេះទុក្ខ នេះហេតុឲ្យទុក្ខកើត នេះ ការរំលត់ទុក្ខ នេះផ្លូវនាំឲ្យដល់ការរំលត់ទុក្ខ (១៥) ។

ខគ្គរសង្កេត ៈ

វិធីធ្វើឲ្យដឹងច្បាស់ នូវអរិយសច្ច គឺចំរើន សមាធិ ។ ឬនិយាយវែងថា ចំរើន សមាធិ និង បញ្ញា ។ ឬ និយាយមួយបែបទៀតថា ចំរើន សមថៈ និង វិបស្សនា ។

បើព្រះពុទ្ធ សម្ដែងច្បាស់យ៉ាងនេះ ពេញគម្ពីរព្រះត្រៃបិដក ម៉េចក៏ស្អប់ សមាធិ ម៉េចក៏បន្ទោសអ្នកធ្វើ សមាធិ ។ ល្មមហើយ ល្មមៗ ហើយ ៕

---

(១៥)-សុត្តន្តបិដក សំយុត្តនិកាយ ៣៩-៣៥៥-២២៦

# សមថៈ វិបស្សនា

៣*៤

ធម៌ ២ យ៉ាង គឺ

១-**សមថៈ** ការអប់រំចិត្តឲ្យស្ងប់

២-**វិបស្សនា** ការអប់រំចិត្តឲ្យមានបញ្ញា ។

ធម៌ ២ យ៉ាងនេះ ហៅថា ភាវេតព្វធម៌ ធម៌ដែលបុគ្គលគប្បីចំរើន គឺបុគ្គលគប្បីធ្វើឲ្យកើតមានក្នុងចិត្តរបស់ខ្លួន[១៦] ។

## សមថៈ

ការអប់រំចិត្តឲ្យស្ងប់ចាកនីវរណធម៌ ហៅថា សមថៈ ។

នីវរណធម៌ មាន ៥ យ៉ាង គឺ

១-**កាមច្ឆន្ទ** សេចក្តីពេញចិត្តក្នុងកាម

២-**ព្យាបាទ** គំនុំ ឬសេចក្តីប្រទូស្ត៍រាយ

៣-**ថីនមិទ្ធៈ** សេចក្តីធុញទ្រាន់ ងោកងុយ

៤-**ឧទ្ធច្ច កុក្កុច្ច** សេចក្តីអណ្តែតអណ្តូង រសាប់រសល់

៥-**វិចិកិច្ឆា** សេចក្តីសង្ស័យ ។

នីវរណធម៌ ៥ យ៉ាងនេះ រារាំងចិត្តមិនឲ្យស្ងប់ មិនឲ្យកើតបញ្ញា មិនឲ្យកើតសេចក្តីសុខ ចំរើន ។

---

[១៦]-សុត្តន្តបិដក ទីឃនិកាយ ១៩-២៥០-២៥៧

បើមើលតាមព្យញ្ជនៈ សមថៈ សំដៅយក ការអប់រំចិត្តឲ្យស្ងប់ តែប៉ុណ្ណោះ ប៉ុន្តែ បើពិចារណាតាមអត្ថ សមថៈ សំដៅយកការអប់រំចិត្តឲ្យមានគុណធម៌ខ្ពស់ឡើង ។ ដូចជាខន្តិ សេចក្តីអត់ធន់ វីរិយៈ សេចក្តីប្រឹងប្រែង មេត្តា ករុណា សេចក្តីរាប់អានអាណិតអាសូរ ជាដើម ទៀតផង ។ និយាយខ្លី គុណធម៌ទាំងឡាយ ក្រៅពីសីល និង បញ្ញា សង្គ្រោះចូលក្នុង សមថៈទាំងអស់ ។

## វិបស្សនា

ការអប់រំចិត្តឲ្យមានបញ្ញា ហៅថា វិបស្សនា ។ បញ្ញាក្នុងទីនេះ មិនសំដៅយកបញ្ញា សំរាប់ប្រកបមុខរបរទេ សំដៅយកចំពោះតែភាវនាមយបញ្ញា បញ្ញាសំរាប់ឃើញច្បាស់នូវសភាវធម៌ (រូបធម៌ និង អរូបធម៌) តាមសេចក្តីពិតរបស់វា តែប៉ុណ្ណោះ ។

## បញ្ញា ៣ យ៉ាង គឺ

១-**ចិន្តាមយបញ្ញា** បញ្ញាចេះគិតគូរមកពីកំណើត ។

២-**សុតាមយបញ្ញា** បញ្ញាកើតពីការរៀនសូត្រពីគេ ។

៣-**ភាវនាមយបញ្ញា** បញ្ញាកើតពីការអប់រំ ការអនុវត្តន៍ ។

វិបស្សនាបញ្ញា សំរាប់កំចាត់បង់ តណ្ហា មានៈ ទិដ្ឋិ ឬ អហង្ការ សេចក្តីសំគាល់ថា អញ ។ មមង្ការ សេចក្តីសំគាល់ថា របស់អញ ។ ជាដើម ។ កំចាត់កិលេសប្រភេទនេះបាន លុះត្រាតែ

គេអប់រំចិត្តឲ្យកើតបញ្ញា ឃើញច្បាស់នូវព្រះត្រៃលក្ខណ៍ អនិច្ចំ ទុក្ខំ អនត្តា ។

## ត្រៃលក្ខណ៍ លក្ខណៈ ៣

១-អនិច្ចតា ឬ អនិច្ចលក្ខណៈ លក្ខណៈមិនទៀង

២-ទុក្ខតា ឬ ទុក្ខលក្ខណៈ លក្ខណៈជាទុក្ខ

៣-អនត្តតា ឬ អនត្តលក្ខណៈ លក្ខណៈជាអនត្តា ។

ត្រៃលក្ខណ៍នេះ មានឈ្មោះហៅម៉្យាងទៀតថា សាមញ្ញ-លក្ខណៈ ប្រែថា លក្ខណៈមានស្មើទូទៅដល់សង្ខារទាំងពួង ដូចនេះក៏បាន ។ តាមទម្លាប់ គេហៅខ្លីថា អនិច្ចំ ទុក្ខំ អនត្តា ត្រឹមប៉ុណ្ណេះ ។

## ឧប្បាទសូត្រ

ព្រះពុទ្ធ សម្តែងថា -

ម្នាលភិក្ខុទាំងឡាយ តថាគត ទាំងឡាយ កើតឡើងក្តី តថាគត ទាំងឡាយ មិនកើតឡើងក្តី ធាតុនោះមាននៅដដែល ។ ធាតុនោះ មាន ៣ គឺ :

១-សព្វេ សង្ខារា អនិច្ចា សង្ខារទាំងឡាយទាំងពួង មិនទៀង,

២-សព្វេ សង្ខារា ទុក្ខា សង្ខារទាំងឡាយទាំងពួង ជាទុក្ខ,

៣-សព្វេ ធម្មា អនត្តា ធម៌ទាំងឡាយទាំងពួង ជាអនត្តា [១៧]។

## អនិច្ចសូត្រ

ព្រះពុទ្ធ សម្ដែងថា -

**រូបំ ភិក្ខវេ អនិច្ចំ វេទនា អនិច្ចា...**

ម្នាលភិក្ខុទាំងឡាយ រូបមិនទៀង វេទនា មិនទៀង សញ្ញា មិនទៀង សង្ខារទាំងឡាយ មិនទៀង វិញ្ញាណ មិនទៀង។

**រូបំ ភិក្ខវេ ទុក្ខំ វេទនា ទុក្ខា...**

ម្នាលភិក្ខុទាំងឡាយ រូប ជាទុក្ខ វេទនា ជាទុក្ខ សញ្ញា ជាទុក្ខ សង្ខារទាំងឡាយ ជាទុក្ខ វិញ្ញាណ ជាទុក្ខ ។

**រូបំ ភិក្ខវេ អនត្តា វេទនា អនត្តា...**

ម្នាលភិក្ខុទាំងឡាយ រូប ជាអនត្តា វេទនា ជាអនត្តា សញ្ញា ជាអនត្តា សង្ខារទាំងឡាយ ជាអនត្តា វិញ្ញាណ ជាអនត្តា ។

---

[១៧]-សុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត ៤១-១៣៨-៤៥៧ អ្នកខ្លះហៅសូត្រនេះថា ធម្មនិយាមសូត្រ ដូចនេះ ក៏មាន ។

ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវក ជាអ្នកចេះដឹងឃើញយ៉ាងនេះ រមែងនឿយណាយនឹងរូបផង នឿយណាយនឹងវេទនាផង នឿយណាយនឹងសញ្ញាផង នឿយណាយនឹងសង្ខារទាំងឡាយផង នឿយណាយនឹងវិញ្ញាណផង កាលបើនឿយណាយរមែងប្រាសចាកតម្រេក កាលប្រាសចាកតម្រេក ចិត្តក៏រួចផុត (ចាកកិលេស) [១៨]។

## អនិច្ចសូត្រ

ព្រះពុទ្ធ សម្ដែងថា -

ចក្ខុំ ភិក្ខវេ អនិច្ចំ ម្នាលភិក្ខុទាំងឡាយ ភ្នែកមិនទៀង **យទនិច្ចំ តំ ទុក្ខំ** របស់ណាមិនទៀង របស់នោះជាទុក្ខ **យំ ទុក្ខំ តទនត្តា** របស់ណាជាទុក្ខ របស់នោះជាអនត្តា **យទនត្តា តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ** ។ របស់ណាជាអនត្តា របស់នោះ បុគ្គលត្រូវយល់ដោយប្រាជ្ញាដ៏ប្រពៃ តាមពិតយ៉ាងនេះថា នុ៎ះ មិនមែនរបស់អញ នុ៎ះ មិនមែនជាអញ នុ៎ះ មិនមែន ជាខ្លួនរបស់ អញទេ [១៩]។

---

[១៨]-សុត្តន្តបិដក សំយុត្តនិកាយ ៣៣-៣៩-៤៩

[១៩]-សុត្តន្តបិដក សំយុត្តនិកាយ ៣៥-១-១

ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត មានអត្ថន័យ ដែលគេគប្បីយល់ដូចគ្នានឹងភ្នែកនោះផងចុះ ។

ឧត្តរសង្កេត :

១-**សង្ខារ** គឺរបស់រួមផ្សំគ្នា មិនមែនរបស់តែមួយមុខទេ ។ ឧ. រូបកាយមនុស្សយើង រួមផ្សំគ្នាដោយធាតុច្រើនយ៉ាង បើនិយាយតាម ពុទ្ធសាសនា ថា ប្រកបដោយធាតុ ៤ គឺ ដី ទឹក ភ្លើង ខ្យល់ ។ របស់ដែលរួមផ្សំគ្នាយ៉ាងនេះ ហៅថា សង្ខារ ។ ភ្នំ រួមផ្សំគ្នាដោយវត្ថុធាតុច្រើនយ៉ាង ដី ថ្ម ក្រួស ខ្សាច់ ជាដើម ។ របស់ដែលរួមផ្សំគ្នាយ៉ាងនេះ ហៅថា សង្ខារ ។ ផ្ទះ រួមផ្សំគ្នាដោយវត្ថុច្រើនយ៉ាង ឥដ្ឋ ស៊ីម៉ង់ត៍ កំបោរ ឈើ ដែក ជាដើម។ របស់ដែលរួមផ្សំគ្នាយ៉ាងនេះ ហៅថា សង្ខារ ។ល។

សង្ខារ មានច្រើនបែប ច្រើនយ៉ាង ប៉ុន្តែ ក្នុងទីនេះ និយាយដោយខ្លី មាន២ យ៉ាង គឺ :

១-**ឧបាទិន្នកសង្ខារ** សង្ខារដែលមានចិត្ត មានវិញ្ញាណគ្រប់គ្រង ឧ. មនុស្ស សត្វ ជាដើម ។

២-**អនុបាទិន្នកសង្ខារ** សង្ខារដែលមិនមានចិត្ត មិនមានវិញ្ញាណគ្រប់គ្រង ឧ. ភ្នំ ផ្ទះ ជាដើម ។

សង្ខារទាំង ២ យ៉ាងនេះ មានលក្ខណៈ ៣ ជា អនិច្ចំ ទុក្ខំ

អនត្តា ដូចគ្នា ស្មើគ្នាទូទៅ គ្មានលើកលែងសង្ខារណាមួយទេ ។ សង្ខារណា ក៏ប្រែប្រួល ក៏មិនទៀង សង្ខារណា ក៏មានទុក្ខ នៅនឹងដដែលមិនមាន សង្ខារណា ក៏ស្លាប់ ក៏រលត់ ។ មនុស្សចាស់ ក៏ប្រែប្រួល មនុស្សក្មេង ក៏ប្រែប្រួល ផ្ទះ ក៏ប្រែប្រួល ។ បណ្ឌិត ក៏មានទុក្ខ ពាល ក៏មានទុក្ខ ផ្ទះ ក៏មានទុក្ខ (ពុក) ។ នាម៉ឺន ក៏ស្លាប់ រាស្ត្រ ក៏ស្លាប់ ផ្ទះ ក៏ស្លាប់ (ខូច) ។ មានលក្ខណៈ ៣ អនិច្ចំ ទុក្ខំ អនត្តា ដូចគ្នា ស្មើគ្នា គ្រប់សង្ខារ ទាំងឡាយទាំងពួង ប៉ុន្តែ អាចមានជម្ងឺខុសគ្នា តិចច្រើនជាងគ្នា អាយុជីវិតវែងខ្លីខុសគ្នា ដោយអាស្រ័យហេតុបច្ច័យផ្សេងទៀត ។

២-អនត្តា ប្រែថា មិនមែនខ្លួន បើវាពិតជាខ្លួនយើង ជារបស់យើងមែន យើងបង្គាប់វា កុំឲ្យចាស់ កុំឲ្យឈឺ កុំឲ្យស្លាប់ វាស្តាប់បង្គាប់យើង វាធ្វើតាមយើងហើយ ។ ប៉ុន្តែ វាអត់ធ្វើតាមយើងសោះ បានជាគេហៅថា អនត្តា ។ អនត្តា ប្រែថា មិនមានខ្លួន គឺថា មិនមានអ្វី ជាខ្លួន ជាព្រលឹង នៅអាស្រ័យក្នុងខ្លួនយើងនោះទេ មានត្រឹមតែខន្ធ ៥ ប៉ុណ្ណោះ ។

សង្ខារ ទាំងឡាយទាំងពួង ជា អនត្តា ព្រោះគ្មាននរណាបង្គាប់បញ្ជាបាន វិសង្ខារ (ព្រះនិព្វាន) ជា អនត្តា ដែរ ព្រោះ

គ្មាននរណា បង្គាប់បញ្ជាព្រះនិព្វាន ឲ្យចាស់ ឲ្យឈឺ ឲ្យស្លាប់ ឲ្យមានទុក្ខបាន ។ អនត្តា ដូចគ្នាមែន ប៉ុន្តែ អនត្តា របស់សង្ខារ ពេញដោយ ទុក្ខ, អនត្តា របស់ព្រះនិព្វាន ពេញដោយ បរមសុខ ។

ដើម្បីឲ្យពាក្យថា អនត្តា ស៊ីសេចក្តីបានទាំងពីរ ទើបព្រះសក្យមុនី ប្រើពាក្យថា **សព្វេ ធម្មា អនត្តា** ដូច្នេះវិញ ។

សង្ខារទាំងឡាយទាំងពួង

មានត្រៃលក្ខណ៍គ្រប់ទាំង ៣ គឺ :

1-**អនិច្ចំ** មិនទៀង

2-**ទុក្ខំ** ជាទុក្ខ ទ្រាំនៅដដែលមិនបាន

3-**អនត្តា** មិនមែនខ្លួន មិនស្តាប់បង្គាប់ ។

វិសង្ខារព្រះនិព្វាន

មានត្រៃលក្ខណ៍ តែមួយ គឺ អនត្តា

1-**អនិច្ចំ** គ្មាន

2-**ទុក្ខំ** គ្មាន

3-**អនត្តា** បង្គាប់បញ្ជាមិនបាន ។

៣-អ្វី ៗ ដែលប្រកបដោយត្រៃលក្ខណ៍ អនិច្ចំ ទុក្ខំ អនត្តា ព្រះពុទ្ធ ប្រៀនប្រដៅថា -

1-កុំសំគាល់ថាជាខ្លួន ឬ ជារបស់ខ្លួន ព្រោះនាំឲ្យកើតទុក្ខ។

2-កុំស្រឡាញ់ កុំជាប់ចិត្តនឹងវា កុំរែក កុំទូល តទៅទៀត នាំឲ្យកើតទុក្ខ ។

3-ត្រូវដាក់អម្រែកចុះ ត្រូវរលាស់វាចេញ គេចជៀសផុតឲ្យស្រឡះពីវា អស់កង្វល់អ្វី ។ ជាមួយវា ទើបរួចផុតចាកទុក្ខដោយប្រការទាំងពួង ។

## វិមោក្ខ មាន ៣ គឺ

**១-សុញ្ញតវិមោក្ខ**

**២-អនិមិត្តវិមោក្ខ**

**៣-អប្បណិហិតវិមោក្ខ** [២០]។

**សុញ្ញតវិមោក្ខ** តើដូចម្ដេច ។ ភិក្ខុ ពិចារណាដូច្នេះថា នាមរូបនេះ ជារបស់សូន្យ ចាកខ្លួន ឬ ចាករបស់ខ្លួន ភិក្ខុនោះ មិនធ្វើនូវសេចក្ដីប្រកាន់មាំ ក្នុងនាមរូបនោះទេ ហេតុនោះ ទើបឈ្មោះថា សុញ្ញតវិមោក្ខ ។

**អនិមិត្តវិមោក្ខ** តើដូចម្ដេច ។ ភិក្ខុ ពិចារណាដូច្នេះថា នាមរូបនេះ ជារបស់សូន្យ ចាកខ្លួន ឬ ចាករបស់ខ្លួន ភិក្ខុនោះ មិនធ្វើនូវ និមិត្ត ក្នុងនាមរូបនោះទេ ហេតុនោះ ទើបឈ្មោះថា

---

[២០]-សុត្តន្តបិដក ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ ៧០-១៧៧-២៨០

អនិមិត្តវិមោក្ខ ។

**អប្បណិហិតវិមោក្ខ** តើដូចម្តេច ។ ភិក្ខុ ពិចារណា ដូច្នេះថា នាមរូបនេះ ជារបស់សូន្យ ចាកខ្លួន ឬ ចាករបស់ខ្លួន ភិក្ខុនោះ មិនធ្វើនូវសេចក្តីប្រាថ្នា ក្នុងនាមរូបនោះទេ ហេតុនោះ ទើបឈ្មោះថា អប្បណិហិតវិមោក្ខ ។

ខគួរសង្កេត :

**សុញ្ញតវិមោក្ខ** ភិក្ខុ ពិចារណាឃើញ នាមរូប សូន្យ មិនមែនខ្លួន មិនមែនរបស់ខ្លួន គឺ ឃើញអនត្តា ។

**អនិមិត្តវិមោក្ខ** ភិក្ខុពិចារណាឃើញ នាមរូប សូន្យ មិនមាននិមិត្ត ត្រង់ណាមួយថា ទៀង គឺ ឃើញ អនិច្ចំ ។

**អប្បណិហិតវិមោក្ខ** ភិក្ខុ ពិចារណាឃើញ នាមរូប សូន្យ មានតែទុក្ខ មិនគួរប្រាថ្នា គឺ ឃើញ ទុក្ខំ ។

**សុញ្ញតវិមោក្ខ** ការរួចផុតចាកកិលេស ព្រោះឃើញ អនត្តា,

**អនិមិត្តវិមោក្ខ** ការរួចផុតចាកកិលេស ព្រោះឃើញ អនិច្ចំ,

**អប្បណិហិតវិមោក្ខ** ការរួចផុតចាកកិលេស ព្រោះឃើញ ទុក្ខំ ។

លោកលើក អនត្តា ឡើងមុនគេ ព្រោះជាប្រការសំខាន់បំផុត ស្លាប់ រស់ នៅត្រង់ មានខ្លួន ឬ មិនមាន(មិនមែន)ខ្លួនហ្នឹងឯង ៕

## ព្រះនិព្វាន

ព្រះនិព្វាន (ជាវិសង្ខារ) ជាទីរំលត់កិលេស ជាទីរំលត់ទុក្ខ ជាទីពេញដោយសេចក្ដីសុខ ត្រជាក់ត្រជុំ ក្សេមក្សាន្ត យ៉ាងក្រៃលែងជាទីបំផុត ។

ទ្វារចូលដល់ព្រះនិព្វាន មាន ៣ គឺ:

១-ទ្វារ អនិច្ចំ

២-ទ្វារ ទុក្ខំ

៣-ទ្វារ អនត្តា ។

អ្នកត្រូវការចូលដល់ ព្រះនិព្វាន គប្បីចូលតាមទ្វារ ៣ នេះទ្វារណាមួយ ទ្វារដទៃទៀត ក្រៅពីនេះ មិនមានទេ ។

សីល ជា យាន

ទាន ជា ស្បៀង

ភាវនា មិនទៀងៗ ជាកូនសោ សំរាប់ចាក់ចូលព្រះនិព្វាន ។

១-អនិច្ចានុបស្សី ពិចារណាឃើញរឿយៗថា មិនទៀងៗ ដកដង្ហើមចូល-ចេញ,

២-ទុក្ខានុបស្សី ពិចារណាឃើញរឿយៗថា ជាទុក្ខៗ ដកដង្ហើមចូល ចេញ,

៣-អនត្តានុបស្សី ពិចារណាឃើញរឿយៗថា មិនមែនខ្លួនៗ ដកដង្ហើម ចូល-ចេញ ។

សព្វេ សង្ខារា អនិច្ចាតិ យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។
សព្វេ សង្ខារា ទុក្ខាតិ យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។
សព្វេ ធម្មា អនត្តាតិ យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ៕

ពេលណា បុគ្គល ពិចារណាឃើញច្បាស់ដោយបញ្ញាថា សង្ខារទាំងឡាយទាំងពួង មិនទៀង ពេលនោះ គេនឹងនឿយណាយ ក្នុងសេចក្ដីទុក្ខ នុ៎ះ ជាផ្លូវនៃសេចក្ដីបរិសុទ្ធិ ។

ពេលណា បុគ្គល ពិចារណាឃើញច្បាស់ដោយបញ្ញាថា សង្ខារ ទាំងឡាយទាំងពួង ជាទុក្ខ ពេលនោះ គេនឹងនឿយណាយក្នុង សេចក្ដីទុក្ខ នុ៎ះ ជាផ្លូវនៃសេចក្ដីបរិសុទ្ធិ ។

ពេលណា បុគ្គល ពិចារណាឃើញច្បាស់ដោយបញ្ញាថា ធម៌ទាំងឡាយទាំងពួង ជា អនត្តា ពេលនោះ គេនឹងនឿយណាយក្នុងសេចក្តីទុក្ខ នុ៎ះ ជាផ្លូវនៃសេចក្តីបរិសុទ្ធិ [២១]៕

## វិធីចំរើន សមថៈ វិបស្សនា

ឧបករណ៍ មាន ៣ គឺ :

១-ចិត្ត

២-សតិ សម្បជញ្ញៈ (ញាណ)

៣-អារម្មណ៍ (ខ្យល់ដកដង្ហើម)[២២] សំរាប់តម្កល់ចិត្ត និងសតិ។

ភិក្ខុ (យោគី) គប្បីអង្គុយឲ្យត្រង់ខ្លួន

-ដកដង្ហើម ចូល ចេញ មានសតិ សម្បជញ្ញៈ ដឹង ។

-ដកដង្ហើម ចូល ចេញ វែង ដឹងច្បាស់ថា វែង ។

-ដកដង្ហើម ចូល ចេញ ខ្លី ដឹងច្បាស់ថា ខ្លី ។

-សិក្សាថា ដឹងច្បាស់នូវកាយទាំងពួង ដកដង្ហើម ចូល ចេញ ។

---

[២១]-សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា ៥២-៣០-៧៩

[២២]-អារម្មណ៍ជាកុសលណាមួយក៏បាន ។

-សិក្សាថា រម្ងាប់នូវកាយសង្ខារ ដកដង្ហើមចូល-ចេញ ។

ឈ្មោះថា សមថៈ ព្រោះចិត្តស្ងប់ ក្នុងអារម្មណ៍តែមួយ ។ ឈ្មោះថា សមាធិ ព្រោះចិត្តតាំងមាំ ក្នុងអារម្មណ៍តែមួយ ។ ពាក្យទាំងពីរនេះ ផ្សេងគ្នា ប៉ុន្តែ អត្ថន័យ ជាមួយគ្នា ។

ចិត្តស្ងប់ មិនមានការគិត ឬ ពិចារណាអារម្មណ៍ទេ គ្រាន់តែធ្វើចិត្ត ទប់ចិត្តឲ្យស្ងប់ ។ ឲ្យមូលនៅក្នុងអារម្មណ៍តែមួយប៉ុណ្ណោះ ទុកជាត្រឹមត្រូវ ទុកជាបានការ ទុកជាបានបុណ្យហើយ ។ ប៉ុន្តែ បើចិត្តវាមិនស្ងប់ វាចេះតែស្ទុះ ទៅរកអារម្មណ៍ផ្សេង ៗ កុំខឹងនឹងវា ព្រោះនេះជាធម្មតារបស់វា ចិត្តរបស់អ្នកដទៃ ក៏យ៉ាងនេះដែរ ។ អ្នកបដិបត្តិ គប្បីនាំចិត្តមករកអារម្មណ៍របស់កម្មដ្ឋានវិញ ចាប់ផ្តើមវិញ ធ្វើយ៉ាងនេះ ច្រើនដងទៅ យូរ ៗ ទៅ ចិត្តនឹងស្ងប់គ្រាន់បើឡើង ៗ ។

កាលបើចិត្តចាប់ស្ងប់ ល្មមសមគួរហើយ គេអាចចាប់ផ្តើមចំរើនវិបស្សនា គឺពិចារណាអារម្មណ៍នោះ[២៣] ជា រូប នាម ជាហេតុ ផល ឲ្យឃើញ កើត រលត់ ឬ ឲ្យឃើញ អនិច្ចំ ទុក្ខំ អនត្តា ។

ក្នុងពេល ដែលចិត្តស្ងប់ នៅសល់របស់២ គឺ

---

[២៣]-អាចប្តូរជាអារម្មណ៍ណាមួយ របស់ វិបស្សនា ក៏បាន ។

១-ខ្យល់ដកដង្ហើមចូល-ចេញ ២-ចិត្ត កំណត់ដឹង ខ្យល់ដកដង្ហើមចូល-ចេញ ។ ខ្យល់ដកដង្ហើមចូល ចេញ ជារូបធម៌ ព្រោះទទួលអារម្មណ៍មិនបាន ដឹងអារម្មណ៍មិនបាន ។ ចិត្ត ជានាមធម៌ ព្រោះទទួលអារម្មណ៍បាន ដឹងអារម្មណ៍បាន ។ ពាក្យថា ខ្លួនយើង ខ្លួនគេ ទាំងមូលហ្នឹង មានតែរបស់ ២ យ៉ាង គឺ រូបធម៌ និង នាមធម៌ ប៉ុណ្ណឹង គ្មានអ្វីដទៃ ក្រៅពីនេះទេ ។ បើរូបធម៌ និង នាមធម៌ នៅអាស្រ័យគ្នា យើងរស់ យើងមានសកម្មភាព ដើរ ឈរ អង្គុយ ដេក... បាន បើរូបធម៌ និង នាមធម៌ លែងអាស្រ័យគ្នា យើងស្លាប់ ធ្វើអ្វីលែងបានហើយ ។ រូបធម៌ និង នាមធម៌ កើតឡើងអាស្រ័យហេតុ បច្ច័យ បើហេតុបច្ច័យ មិនទៀង រូបធម៌ នាមធម៌ ក៏មិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាមិនទៀងផង ជាទុក្ខផង របស់នោះ ជាអនត្តា ។ ក្នុងរូបធម៌ នាមធម៌នោះ គ្មានអ្វីជាខ្លួន ជារបស់ខ្លួនទេ ដូចនេះ កុំសម្គាល់ថា អញ ថា របស់អញ ព្រោះការសម្គាល់យ៉ាងនេះ នាំឲ្យកើតទុក្ខ ។

ខ្លួនយើង ជារូបធម៌ នាមធម៌ របស់ដែលយើងអាស្រ័យ ជារូបធម៌ នាមធម៌ របស់នៅជុំវិញ ជារូបធម៌ នាមធម៌ របស់ក្នុងពិភពលោក ជារូបធម៌ នាមធម៌ អ្វី ៗ ក៏សុទ្ធតែជារូបធម៌ នាមធម៌ ។ ខ្លួនយើង ជារូបធម៌ នាមធម៌ផង យើងរស់

នៅជាមួយ រូបធម៌ នាមធម៌ ផង តើធ្វើដូចម្ដេច កុំឲ្យមានទុក្ខច្រើនពេក ល្មមយើងអត់ធន់បានផង ។ វិធីដែលល្អ គឺ សិក្សាឲ្យស្គាល់ច្បាប់ធម្មជាតិ ឲ្យស្គាល់ច្បាប់ព្រះត្រៃលក្ខណ៍ ហើយគោរពតាមច្បាប់នោះ កែសម្រួលតាមច្បាប់នោះ ហើយកុំទាមទារអ្វី ។ និងកុំមានតណ្ហា មានៈ ទិដ្ឋិ ប្រកាន់មាំនូវអ្វីៗក្នុងលោកឡើយ ។

## អានិសង្ស

នៃការចំរើន សមថៈ វិបស្សនា

គ្មានបុណ្យណា ទោះជាបុណ្យបច្ច័យ ៤ បុណ្យកឋិន បុណ្យកសាងសេនាសនទាន ស្ពាន ថ្នល់ និង បុណ្យអ្វីផ្សេងៗទៀត មានផលានិសង្សផ្ទឹមស្មើ នឹងបុណ្យចំរើន សមថៈ វិបស្សនា បានទេ ។ សមថៈ វិបស្សនា ជាបុណ្យ មានផលានិសង្ស ច្រើនជាងបុណ្យណាៗទាំងអស់ ។

**ចូរខំចំរើន សមថៈ វិបស្សនា ឲ្យច្រើនឡើង ៗ ជារៀងរាល់ថ្ងៃ អ្នកនឹងបានសម្រេច មគ្គផល ជាពុំខាន ៕**

យើងខ្ញុំ សូមឧទ្ទិសចំណែកបុណ្យកុសលនេះ ចំពោះលោក អ្នក ដ៏មានគុណទាំងឡាយ មានមាតាបិតា ជីដូនជីតា គ្រូឧបជ្ឈាយាចារ្យ និង ញាតិកាសាលោហិត មិត្រសំឡាញ់ជាដើម ។ សូម លោក អ្នក ដ៏មានគុណទាំងឡាយជាដើមនោះ អនុមោទនា ចំពោះបុណ្យកុសលនេះ ហើយទទួលយក នូវឥដ្ឋ-មនុញ្ញផល ជាទីគាប់ចិត្ត កុំបីអាក់ខានឡើយ ៗ៚

មគ្គានដ្ឋង្គិកោ មគ្គោ

ផ្លូវប្រកបដោយអង្គ ៨ ប្រសើរជាងផ្លូវទាំងឡាយ

សច្ចានំ ចតុរោ បទា

សច្ចទាំងឡាយ ៤ ប្រសើរជាង សច្ចទាំងឡាយ

យើងខ្ញុំជាកូន ខ្ចៅ យុនសំរ៉ង ខ្ចៅ យ៉ាតណៃ ខ្ចៅសុខផល ខ្ចៅ វិសាល ខ្ចៅ រ៉ាមុន
ខ្ចៅ ភារាដា ខ្ចៅ ចំរើន ខ្ចៅ ភារី

បានឧបត្ថម្ភការផ្សាយសៀវភៅនេះជាeBook
ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ ឧបាសក ខ្ចៅ ពាញ និង ឧបាសិកា ឈរ យឿន

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

**មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ**

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ **ទាវ បញ្ញា**

សីហា ឆ្នាំ ២០១៥

បើលោក-លោកស្រីចង់បានសៀវភៅនេះ ឬអានបន្តទៅទៀត សូមទិញ ឬជាវពីអ្នកនិពន្ធ
ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធិ" របស់អ្នកនិពន្ធ។
យើងខ្ញុំ ពុំមានការប្រាស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយអ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ
ខ្ចៅ យុនសំរ៉ង
ប្រធាន
មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org

វត្តពោធិវង្ស
101, Boulevard de la République
77420 Champs sur Marne
Tél : 01 60 06 44 98
Fax : 01 64 62 17 41

# កាន់ពុទ្ធសាសនា

៙❁៚

គេកាន់ពុទ្ធសាសន៍សុខចំរើន    ភោគផលកើតកើនច្រើនសុខា
សម្បូណ៌សប្បាយគ្រប់អាត្មា    រុងរឿងថ្លៃថ្លាដោយសារពុទ្ធ ។

ឯងកាន់ពុទ្ធសាសន៍ដូចគេដែរ    តែបាក់បែកបែរប្រែចុះស្រុត
ពលរដ្ឋស្រែកយំសែនរន្ធត់    ជាតិធ្លាក់ទុគ៌តគួរឲ្យព្រួយ ។

រឿងនេះ តើមកពីនរណា    មកពីសាសនាមិនគិតជួយ
ឬ ពួកមន្ត្រីពុករលួយ    ដឹងហើយត្រូវជួយកែលំអ ។

រួមគ្នាសាងជាតិ និង សាសនា    ចំរើនផលាស្រូវអង្ករ
អប់រំកាយចិត្តប្រព្រឹត្តធម៌    ត្រឹមត្រូវបវរតរៀងទៅ ។

រីឯអ្នកដែលធ្វើខុសវិញ    ត្រូវឆាប់ចុះចេញកុំក្រាញនៅ
ដើម្បីជាតិយើងរស់តទៅ    សាសនាគង់នៅរីកថ្កើងថ្កាន ។

ពួកអ្នកគាំទ្រក៏ដូចគ្នា    ត្រូវឈប់ការពារចោរសាមាន្យ
ទម្លាក់វាចុះអស់រំខាន    ជាតិសាសន៍យើងបានសុខសាន្តហោង៕

**រោងពុម្ព អមរា**
**Tel: 012 726 756 / 097 7 729 756**
**Email: amaraprintinghouse@yahoo.com.au**